# អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

# BUDDHISM FOR SOCIAL DEVELOPMENT ACTION

## របាយការណ៍សកម្មភាពប្រចាំឆ្នាំ ២០១៩

### ចាប់ផ្តើម ខែ មករា ដល់ ខែធ្នូ

### ផ្ញើដោយ

អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម
Buddhism for Social Development Action

---

**ទំនាក់ទំនង ៖ លោក ថន វណ្ណុង**

**នាយកប្រតិបត្តិអង្គការ**

ផ្លូវជាតិលេខ៧ ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ប្រទេសកម្ពុជា

ទូរសព្ទ័.: (+៨៥៥) ៤២ ៥០ ៧៧ ៩៩៩/០១២ ៧៨៨ ៩៧៣

គេហទំព័រ: www.bsda-cambodia.org

សារអេឡិចត្រូនិច: director@bsda-cambodia.org

# មាតិកា


១. សេចក្តីផ្តើម ........ 4

ក. ប្រវត្តិអង្គការ ........ 4

ខ. អត្តសញ្ញាណអង្គការ ........ 4

គ. ការកំណត់នូវគុណតម្លៃ ........ 4

ឃ. ទស្សនៈវិស័យ ........ 5

ង. បេសកកម្ម ........ 5

ច. គោលដៅរបស់អង្គការ ........ 5

២. សកម្មភាពរបស់អង្គការ ........ 6

២.១). កម្មវិធីអប់រំ ........ 6

២.១.១). គម្រោងកុមារមេគង្គកម្ពុជា (Mekong Kampuche Kids Project) ........ 6

១, ផ្តល់អាហារូបករណ៍ ........ 7

២). កុំព្យូទ័រ និងអង់គ្លេស ........ 7

៣). បណ្តុះបណ្តាលបំនិនជីវិតផ្នែក របាំប្រពៃណីខ្មែរ និងភ្លេង ........ 8

៤). មណ្ឌលសប្បាយសប្បាយ ........ 99

៥). មណ្ឌលនៃក្តីញញឹម ........ 9

៦). សាលាថ្នាក់បម្រុងបន្ថែមនៅវិទ្យាស្ថាន នៃក្តីញញឹម ........ 11

៧). កម្មវិធីថែទាំសុខភាពបឋមនៅមណ្ឌលកុមារ ........ 11

៨). កម្មវិធី ថែទាំបន្ត ........ 12

២.១.២). គម្រោងការអប់រំជាមូលដ្ឋាន (Basic Education Project) ........ 12

១). អ្នកទទួលផលសរុប ........ 13

២). លទ្ធផលដែលសម្រេចបាន ........ 13Error! Bookmark not defined.

២.១.៣). គម្រោងអប់រំអនាគតកុមារ Child"s Future Education Project) ........ 15

១). អ្នកទទួលផលសរុប ........ 16

២). លទ្ធផលដែលសម្រេចបាន ........ 16

៣). បញ្ហាប្រឈម ........ 12

៤). ដំណោះស្រាយ ........ Error! Bookmark not defined.

៥). សំណូមពរ ........ 12

២.២). កម្មវិធីសុខភាព .......................................................................................................... 211
២.២.១). គម្រោងផែនការគ្រួសារ (Family Planning Project) .....................Error! Bookmark not defined.1
១). ការទំនាក់ទំនងដើម្បីអោយមានការផ្លាស់ប្តូរទៅលើមធ្យោបាយពន្យារកំណើត (ការអប់រំ).....Error! Bookmark not defined.2
២). ការបញ្ជូនស្ត្រីទៅទទួលការប្រឹក្សា និងប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើប ........Error! Bookmark not defined.3
២.២.២).- គម្រោងអាជីវកម្មខ្នាតតូច (Financing Future Project) .................................................. 2626
១). ផ្តល់ការបណ្តុះបណ្តាល ផ្នែកអាជីវកម្មខ្នាតតូច និងផ្តល់ប្រាក់កំចី មុនពេលដែលយើងបានផ្តល់នូវប្រាក់កម្ចី....... 2628
២). ចុះត្រួតពិនិត្យ និងបង្រៀនការចិញ្ចឹម ..........................................................................................26
៣). ការបង្កើតប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុន ............................................................27
៤). ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់..............................................................................................27
២.២.៣ - គម្រោង៖ ការធ្វើអោយប្រសើរឡើងនូវជីវភាព (Chicken Raising Project) ..................................28
១). ផ្តល់ការបណ្តុះបណ្តាល ផ្នែកចិញ្ចឹមមាន់ និងផ្តល់ប្រាក់ទុន មុនពេលដែលយើងបានផ្តល់នូវប្រាក់ទុន ..................28
២). ចុះត្រួតពិនិត្យ និងបង្រៀនការចិញ្ចឹមមាន់ ........................................................................................28
៣). ការបង្កើន ប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុននៃការចិញ្ចឹមមាន់ .......................................29
៤). ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់..............................................................................................29
២.៣ - កម្មអភិបាលកិច្ចល្អ .......................................................................................................................30
២.៣.១). គម្រោងគណនេយ្យភាពសង្គម ធ្វើឲ្យប្រសើឡើងនូវសេវាសាធារណៈ ..................................................30
១). លទ្ធផលសម្រេចបាន .......................................................................................................................29
២). បញ្ហាប្រឈម និងដំណោះស្រាយ .........................................................................................................29
៣. សន្និដ្ឋាន ........................................................................................................................................26

# របាយការណ៍ស្តីពីលទ្ធផលការងារ
# សម្រាប់ឆ្នាំ ២០១៩

## ១. សេចក្តីផ្តើម៖

### ក. ប្រវត្តិអង្គការ

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍសង្គម (BSDA) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលបានបង្កើតឡើងនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០៥ ដោយព្រះសង្ឃ៧អង្គនៅវត្ត នគរបាជ័យ និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ តាមប្រកាសលេខ ១៦២ ស.ជ.ណ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០០៥ ។ BSDA មិនធ្វើការបម្រើឱ្យគណបក្សនយោបាយណា ឬក៏ផ្សព្វផ្សាយ ពីសាសនា របស់សមាជិកខ្លួនឡើយ។ BSDA គឺផ្តោតតែលើការអភិវឌ្ឍន៍សង្គម និងជួយប្រជាជនក្រីក្រ ដែលកំពុង រស់នៅក្នុងសហគមន៍ក្រីក្រ។

### ខ. អត្តសញ្ញាណអង្គការ

BSDA គឺជាអង្គការធ្វើការជាមួយសហគមន៍ ដែលត្រូវបានបង្កើតឡើងនៅលើគោលការណ៍ ព្រះពុទ្ធសាសនានៃមេត្តាធម៌ដើម្បី ផ្តល់អំណាយដល់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះនិងដើម្បី លើកកំពស់ការចូលរួមទំនាក់ទំនងល្អដោយ ក្តីអាណិតស្រឡាញ់នៅក្នុង សង្គម ហើយជួយធ្វើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ចកាន់តែខ្លាំង ដើម្បីរួមចំណែកលុបបំបាត់ភាពក្រីក្រនិងសេចក្តីទុក្ខដែលអាចជៀសផុតបាន។

### គ. ការកំណត់នូវគុណតម្លៃ

ដោយផ្អែកទៅលើពាក្យប្រៀនប្រដៅពីការអនុវត្តធម៌មេត្តារបស់ព្រះពុទ្ធអង្គ[1]BSDAបានគោរពតាមនូវគុណតម្លៃដូចខាងក្រោម៖

- **បំរើជនក្រីក្រ:** ធ្វើអោយបានប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារដែលក្រីក្រ។
- **រួបរួមសាមគ្គី:** កសាងនូវការជឿជាក់គ្នា ភាពស្មោះត្រង់ និងការគោរពគ្នាទៅវិញទៅមកជាគ្រួសារតែមួយ។
- **យុទ្ធសាស្ត្របែបប្រជាធិបតេយ្យ:** លើកតម្កើងអោយមានសម្លេងរួមគ្នា មកពីសមាជិកសហគមន៍ដៃគូធ្វើការជាមួយ បុគ្គលិកគ្រប់លំដាប់ថ្នាក់ និងការភ្ជាប់ពួកគេទៅនឹងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត។
- **ការសហការគ្នា:** ធ្វើការទាំងអស់គ្នា និងជាដៃគូជាមួយអ្នកផ្សេងៗដែលមកពីទីណាក៏ដោយអោយតែអាច ដើម្បីពង្រីកផលជះរបស់ពួកយើង។

---

1 មេត្តា = ការសាបព្រួសនូវការស្រលាញ់ដែលមិនអាត្មានិយម ហើយនិងក្តីមេត្តា ជាជាងសាបព្រួសនូវភាពជាមិត្តដែលផ្អែកលើផលប្រយោជន៍ផ្ទាល់ខ្លួន។

- **សុចរិតភាព និងគណនេយ្យភាពៈ** នៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ ត្រូវប្រកបដោយគណនេយ្យភាពនិងតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយនិងអ្នកធ្វើការជាមួយគ្នា។

### ឃ .ទស្សនៈវិស័យ

BSDA ប្រថ្នាចង់ឃើញសង្គមមួយ ដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យ និងអាចចិញ្ចឹមជីវិតដោយខ្លួនបាន។

### ង .បេសកកម្ម

បេសកកម្មរបស់BSDA គឺលើកកំពស់ជីវភាពរស់នៅរបស់ប្រជពលរដ្ឋ ដែលងាយរងគ្រោះ ជាពិសេសស្រ្តី និងកុមារ និងយុវជន តាមរយៈវស័យអប់រំ សុខភាព និងការផ្តួចផ្តើមអភិវឌ្ឍន៍ ជីវភាព ការរស់នៅជាដៃជាមួយអ្នកផ្សេងទៀត។

### ច .គោលដៅរបស់អង្គការ

-ដើម្បីជួយដល់កុមារនិងយុវជនដែលងាយរងគ្រោះ អោយមានភាពប្រសើរក្នុងការទទួល បានការអប់រំ និងលើសពីនេះទៅទៀតយុវជនត្រូវបានផ្តល់នូវជំនាញបច្ចេកទេសតាមរយៈ ការបណ្តុះ បណ្តាលវិជ្ជាជីវៈដែលធានាអោយមានជីវភាពប្រកបដោយនិរន្តរភាព។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសហគមន៍ តាមរយៈការអាចកាន់តែទទួលបានសេវាថែទាំសុខភាពតាមសហគមន៍ ដែលប្រកបដោយគុណភាព និងធ្វើអោយយល់ដឹងពីផ្នែកសំខាន់ៗ នៃសុខភាពសាធារណៈកាន់តែល្អប្រសើរឡើង។

-ដើម្បីអោយប្រសើរឡើង ត្រៀមសម្រាប់ការផ្លាស់ប្តូរអាកាសធាតុ ដោយការបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

-ដើម្បីធ្វើអោយមានអភិបាលកិច្ចកាន់តែល្អ ជាការថែមទៅលើផែនការដែលមានស្រាប់ និងការផ្តល់ សេវាសាធារណៈក្នុងការបំពេញនូវតម្រូវការសហគមន៍អោយបានរឹងរិតតែល្អ។

-ដើម្បីធ្វើអោយប្រជាពលរដ្ឋនៅជនបទ ដែលមិនទួលបានផលប្រយោជន៍អ្វី អោយមានឱកាសអាចបង្កើតចំណូលបាន និងគាំទ្រអោយមាននិរន្តរភាព និងបង្កើតសកម្មភាព ដែលមិនរកប្រាក់កម្រៃចំណេញរបស់អង្គការ ដើម្បីពង្រីកផលអោយបានកាន់តែប្រសើរថែមទៀត។

## ២. សកម្មភាពរបស់អង្គការ

### ២.១- កម្មវិធីអប់រំ

### ២.១.១. គម្រោងកុមារមេគង្គកម្ពុជា

ក. គោលបំណង ៖ ជួយគាំទ្រដល់ក្មេងកំព្រា ងាយរងគ្រោះ ក្មេងបាត់បង់ឱកាស និងក្មេង ដែលនៅតាមចិញ្ចើមថ្នល់ ផ្តល់គុណភាពនៃការរស់នៅរបស់ពួកគេ អោយកាន់តែប្រសើរឡើង។

ខ. ចំនួនបុគ្គលិកសរុប ៖ ២៤នាក់ ស្រី ១៤ នាក់

គ. ទីតាំងគម្រោង ៖ ខេត្តកំពង់ចាម វត្តនគរបាជ័យក្នុង

ឃ. សរុបថវិកាគម្រោង ៖ ១៩៧,៦៣៧.៥៤ ដុល្លា

ង. កាលបរិច្ឆេទគម្រោង ៖ ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩

ច. សកម្មភាពអនុវត្តគម្រោង៖

| **ក្រុមកុមារ** OVC | **អ្នកទទួលផលផ្តល់ពីគម្រោង ចាប់ពី ខែ មករា- ខែធ្នូ ២០១៩** | |
|---|---|---|
| | **សរុប** | **ស្រី** |
| I-អាហារូបករណ៍: | | |
| 1. អាហារូបករណ៍សិស្សក្រីក្រនៅសហគមន៍ | ៩០ | ៦១ |
| 2. អាហារូបករណ៍ ម្តាយធម៌ | 0 | 0 |
| 3. អាហារូបករណ៍ កុំព្យូទ័រ | 0 | 0 |
| 4.អាហារូបករណ៍ រៀនភាសាអង់គ្លេស | ៤៣០ នាក់ ជាសិស្សមកពីអាហារូបករណ៍សិស្សក្រីក្រនៅសហគមន៍ | ២៦១ ស្រី នាក់ជាសិស្សមកពីអាហារូបករណ៍សិស្សក្រីក្រនៅសហគមន៍ |
| II-សិស្សបណ្តុះបណ្តាលវិជ្ជាជីវ | ៨២ | ៣០ |
| III. សិស្សថៃទាំបន្ត (សិស្សចប់ជំនាញ) | ៦៨ | ២៩ |
| IV-បណ្តុះបណ្តាលបំនិនជីវិតផ្នែក របាំប្រពៃណីខ្មែរ និងភ្លេង | | |
| 1. សិស្សមណ្ឌលអប្សរា | ៧៨ | ៥៥ |
| 2. សិស្សមណ្ឌលសប្បាយសប្បាយ | ៣៦ | ២២ |
| សរុប | ៧៨៤ | ៤៥៨ |

## ១- ផ្តល់អាហារូបករណ៍

ក្នុងឆ្នាំ២០១៩គម្រោងកុមារមេគង្គកម្ពុជាបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រតាមសាលា ក្នុងស្រុកកំពង់សៀម និងស្រុកកំពង់ចាម សរុប សិស្ស ៩០នាក់ (ស្រី ៦១) ក្នុងនោះសិស្សម្នាក់ទទួលបាន អង្ករ ២៥គីឡូ ប្រេងឆា១ដប ស្ករ១គីឡូ អំបិលអ៊ីយ៉ូត០.៥គីឡូ ទឹកត្រី១ដប ទឹកស៊ីអ៊ីវ១ដប និងត្រីខ២កំប៉ុង ស្មើរនឹងទឹកប្រាក់ចំនួន១៥ដុល្លារសហរដ្ឋអាមេរិចជារៀងរាល់ខែ។ ក្រៅពីនេះគម្រោងបានផ្តល់សម្ភារសិក្សាដល់សិស្សទាំងអស់ក្នុងម្នាក់ៗទទួលបាន សៀវភៅ ប៊ិច ខ្មៅដៃ បន្ទាត់ ជ័រលប់ កាប៉ូក និងសំលៀកបំពាក់១កំផ្លេក្នុងមួយឆ្នាំ។ អាហារូបករណ៍នេះផងដែរទទួលបានជំនួយពីអង្គការ **អេភូសូលីដា**នៅប្រទេសស្វីសតាមរយៈ**អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម។**

ក្នុងឆ្នាំ២០១៩នៃវគ្គរបស់**គម្រោងកុមារមេគង្គកម្ពុជា**គម្រោងបានជួយសម្រួលដល់សិស្សានុសិស្សដែលមានជីវភាពក្រលំបាកដែលមានផ្ទះនៅឆ្ងាយពីសាលា និងសិស្សដែលរៀនពូកែបានពន្ទុខ្ពស់ក្នុងថ្នាក់នៅកង់មួយគ្រឿងដើម្បីជាការលើកទឹកចិត្តដល់អាណាព្យាបាល ក៏ដូចសាមីខ្លួនផងដែរ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
| --- | --- |
| សិស្សមួយចំនួនតូច នៅតែបោះបង់ការសិក្សាទោះបី គម្រោងបានលផ្តល់អាហារូបករណ៍ ដើម្បីគាំទ្រដល់ពួកគេដោយ។ នេះដោយសារការ គាំទ្ររបស់យើង មិនបានគ្រប់គ្រាន់ សម្រាប់គ្រួសាររបស់ធំពួកគេ ដូច្នេះពួកគាត់សម្រេចចិត្តឈប់រៀនដើម្បីរកប្រាក់ចំណូលជួយគ្រួសារវិញ | គម្រោងបានទៅជួបអាណាព្យាបាលដើម្បីពិគ្រោះយោបល់ និងស្វែងរកមូលហេតុអោយបាន ច្បាស់ថា តើហេតុអ្វីបានជាពួកគាត់ត្រូវការ គាំទ្រច្រើន។ គម្រោងនឹងព្យាយម ជជែកជាមួយម្ចាស់ជំនួយ ក្នុងការផ្តល់អាហារូបករណ៍ច្រើនជាងមួយក្នុងមួយគ្រួសារ ប្រសិនបើពួកគេពិតជាត្រូវការការគាំទ្រសម្រាប់ក្រុមគ្រួសារធំរបស់ពួកគេ។ |

## ២- កុំព្យូទ័រ និងភាសាអង់គ្លេស (ថ្នាក់ភាសាអង់គ្លេស)



ថ្នាក់បង្រៀនកុំព្យូទរ័ គម្រោងបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ នៅកំរិតអនុវិទ្យាល័យ ចំនួន ៤០នាក់ (ស្រី ២៧)។ វគ្គសិក្សាមាន គ្រប់គ្រង់រដ្ឋបាលទូទៅ(Microsoft Words, Excel, Power Point, Photoshop, Publisher) និង Computer Repair ដែលបង្រៀនដោយគ្រូស្មគ្រ័ចិត្ត ព្រះតេជគុណ ហេង ហឿន មកពីវត្តនគរបានជ័យក្នុង ហើយជា បុគ្គលិកផ្នែកពត៌មានវិទ្យារបស់អង្គការដែរ។



ការផ្តល់ការសិក្សាថ្នាក់ភាសាអង់គ្លេសបន្ថែម មានបួនកន្លែង នៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវ: (មណ្ឌលកុមារវាលស្រែ)

ចំនួន ២៥នាក់ ស្រី១៩នាក់, មណ្ឌលអប្សរា ១៨នាក់ ស្រី១៨នាក់, បណ្ឌលសប្បាយសប្បាយ ១០១នាក់ ស្រី ៥០នាក់ សិស្សទាំងអស់ ត្រូវបាន បង្រៀនដោយឥតគិតថ្លៃ
និងការអប់រំសីលធម៌សង្គម ដើម្បីបន្ទន់ឥរិយាបថ សម្រាប់ប្អូនៗ ជំនាន់ថ្មី។ រីឯថ្នាក់ភាសាអង់គ្លេសនៅ បឋមសិក្សានិងអនុវិទ្យាល័យអង្គុយរៀងរាល់ម៉ោង ៥ ដល់ ម៉ោង ៧ល្ងាច ទទួលបានសិស្សចំនួន ៥៩១នាក់ ស្រី ៣២៦នាក់ ពួកគាត់ ទទួលបានចុះតម្លៃ ៥០% ធៀបទៅនឹងសាលាឯកជន ដែលគេយក ១០០% សម្រាប់សិស្សក្រីក្រ។

## ៣- បណ្តុះបណ្តាលបំនិនជីវិតផ្នែក របាំប្រពៃណីខ្មែរ និងភ្លេង



នៅមណ្ឌលសិល្បៈអប្សរា បានបណ្តុះបណ្តាលដល់ក្មេងៗ ដែលនៅជុំវិញវត្តនគរបាជ័យ និងក្មេងនៅក្នុង សហគមន៍មួយចំនួន៧៨នាក់ សិស្សស្រីមានចំនួន ៥៥នាក់។ គម្រោងបានដឹកជញ្ជូនពួកគាត់ពីសហគមន៍មកកាន់មណ្ឌល និងពីមណ្ឌលទៅកាន់សហគមន៍វិញដោយប្រើយានជំនិះកង់បីជារៀងរាល់ថ្ងៃដើម្បីកុំអោយពួកគាត់ពិបាកក្នុងការធ្វើដំណើរ។ ក្នុងការមករៀន នៅពេលកំពុងរៀននៅទីនេះអង្គការបានផ្តល់អាហារសម្រន់ជារៀងរាល់ថ្ងៃដល់សិស្សានុសិស្ស។ ជាលទ្ធផលពួកគាត់អាចសំដែងជូនភ្ញៀវ និងពិធីផ្សេងៗបាន ដូចជារបាំជូនពរ នារីជាជួរ អប្សរា គោះត្រឡោក ក្រមា ក្អោកបៃលីន បុកលក្ខ ឆៃយ៉ាំ... និងរបាំត្រុដិជាដើម។ សម្រាប់សិស្សតូចៗ ត្រូវបានផ្តល់ការបណ្តុះបណ្តាលបន្តពីសិស្សលោកគ្រូរបាំផ្ទាល់ និងសិស្សច្បងជាបន្តបន្ទាប់។ ឆ្នាំនេះផងដែរ ក្រុមសិល្បៈដែលដឹកនាំដោយលោកគ្រូរបាំបានចេញសំដែងរបាំបានចំនួន២១ដងតាមកម្មវិធីផ្សេងៗក្នុងខេត្តកំពង់ចាម និងខេត្តផ្សេងទៀតបានយ៉ាងល្អ ប្រកបដោយទំនុកចិត្តខ្ពស់ពីអតិថិជន។



ចំណែកភ្លេងប្រពៃណីមានសិស្សសរុបចំនួន១៥នាក់ (សិស្សស្រីមានចំនួន៩នាក់) ដែលចេញមកពីក្បួស្សរបាំពួកគាត់ទទួលបានការបង្ហាត់ភ្លេងពិណពាទ្យ និងភ្លេងប្រពៃណីខ្មែរ(ភ្លេងការ) បង្ហាត់ដោយលោកគ្រូហុន ម៉េងហុងដែលជំនាញភ្លេងប្រពៃណី និងអាយ៉ៃ និងជាអតីតសិស្សពិការភ្នែកមកពីអង្គការគ្រួសារថ្មី។ រាល់បទភ្លេងដែលបានបង្រៀនគឺសាច់ភ្លេងទូទៅ និងសាច់ភ្លេងសម្រាប់បង្គុំរាំរបាំប្រពៃណី និងអប្សរា។ ជាលទ្ធផលក្នុងឆ្នាំ២០១៩លោកគ្រូភ្លេងបានដឹកនាំកូនក្រុមចេញសំដែងបានចំនួន១១ដងក្នុងកម្មវិធីផ្សេងៗទាំងក្នុងខេត្ត និងក្រៅខេត្ត។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សិស្សរៀនភ្លេងឧស្សាហ៍ភ្លេច | រំលឹកម្នាក់ដងៗ ហើយនឹងធ្វើការសាកល្បងសម្ថភាពតាមរយប្រលង បន្ទាប់មករំលឹកជាក្រុមធំ។ |

## ៤- មណ្ឌលសប្បាយសប្បាយ

នៅមណ្ឌលសប្បាយសប្បាយ គម្រោង កុមារមេគង្គកម្ពុជា ហៅកាត់ថា (MKK) និងគម្រោងសមាគមន៍គម្ពុជាដើម្បីកុមារក្រៅ សាលា (CCOSC) បានកំពុងអនុវត្ត គម្រោងអប់រំ ក្រៅប្រពន្ធ័ គឺបង្រៀនចំណេះដឹងទូទៅ សុខភាព អនាម័យ និង ភាសាអង់គ្លេសត្រៀមមុនចូលរៀន និងកំពុងសិក្សា។ សរុបឆ្នាំ២០១៩នេះ សិស្ស ដែលបាន ទទួលសេវាពីមណ្ឌលសប្បាយសប្បាយមានចំនួនសរុប៣៦នាក់ (សិស្សស្រីមានចំនួន២២នាក់)។ លើសពីនេះទៀត បុគ្គលិកគម្រោងបានចុះផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍ ស្ដីអំពី ផលលំបាកការប្រើអំពើហឹង្សារក្នុងគ្រួសារ សិទ្ធិកុមារ សារៈសម្ខាន់នៃការសិក្សា ពលកម្មកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់អាណាព្យាបាលរបស់សិស្សទាំងអស់ ចំនួន ១២ដង ដែលមានអ្នកចូលរួមសរុប ៨៥០នាក់ (ស្រី៦១៦) នៅតាមសហគមន៍គោលដៅ។ ជាលទ្ធផលធ្វើអោយកូនៗរបស់ពួកគាត់មានចំណេះដឹងកើន ឡើង អត្រាបោះបង់សាលាមានការថយចុះបង់ ការសិក្សារបស់ពួកគាត់ប្រសើរជាមុន។ យោងតាមការធ្វើតេស្តប្រឡងបង្ហាញអោយឃើញថា ៧៩% នៃសិស្សនៅមណ្ឌលសប្បាយសប្បាយ មានពិន្ទុកំរិតល្អ ៨%ល្អបង្គួរ ៣១%មធ្យម ហើយ ៦១%ដែលពិន្ទុទាប នេះបើយោងតាមលទ្ធផលឆ្នាំកន្លងមកមានការកើនឡើងខុសពីធម្មតា។

ចំពោះអាគារ និងបរិវេណមណ្ឌលសប្បាយសប្បាយ ត្រូវបានអនុញ្ញាតិពីមន្ទីរសង្គមកិច្ច ខេត្តកំពង់ចាមអោយប្រើប្រាស់ និងអោយមានការកែឆ្នៃ ឬសង់បន្ថែម និងកែលំអរផ្សេងៗ ដើម្បីជាប្រយោជន៍ដល់កុមារក្រីក្រនៅសហគមន៍នៃក្រុងកំពង់ចាម។ ក្នុងឆ្នាំកន្លងមករហូតដល់ឆ្នាំ ២០១៩ មណ្ឌលសប្បាយសប្បាយបានសង់របង ធ្វើអំពីលួសបន្លាពទ្ធ័ជុំវិញ ភ្លោងទ្វារ ចាក់ដីដារបំពេញ លាបថ្នាំពណ៌អាគារឡើងវិញ ជួសជុលបន្ទប់ទឹក សង់ទីធ្លាសួនកុមារ និងសម្អាតបរិស្ថានជុំវិញបរិវេណមណ្ឌលបានលទ្ធផលប្រសើរគួរអោយកត់សំគាល់ពីអាណាព្យាបាលក៏ដូចញាតិមិត្តជិតខាងផងដែរ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សិស្សមករៀនចំរុះគ្នា និងមានច្រើនកំរិត។ | ចែកក្លាររៀនជាមួយជាពីរតាមអ្វីដែលអាចធ្វើបានក្នុងការបង្រៀន។ |

## ៥- មណ្ឌលនៃក្ដីញញឹម

ក្នុងឆ្នាំ ២០១៩ នៅចុងឆមាសទីIIសិស្សជំនាន់ទីVII បានបញ្ចប់វគ្គចំនួន ២៥នាក់ សិស្សស្រីមានចំនួន៨ ហើយអង្គការ បានធ្វើសមាហារណកម្មពួកគាត់ទៅសហគមន៍វិញ។ ចំណែកជំនាន់ទីVIIIបានចាប់ផ្តើមបន្តវគ្គថ្មី ក្នុងឆមាសទីI សិស្សមានចំនួន ៣៥នាក់ បូករួមទាំងសិស្សសាលារដ្ឋ១០នាក់ (សិស្ស

ស្រីមានចំនួន១៦) ក្នុងនោះមានសិស្សពីរនាក់ ដែលបានធ្វើសមាហារណកម្ម ពីអង្គការ ផ្ទះកុមារ ខេត្តកំពង់ចាម និង វត្តអំពត ខេត្តតាកែវ។ ក្នុងឆ្នាំនេះមណ្ឌលបានកើន សិស្ស ២នាក់បន្ថែមទៀត។

## ក- ការងារសាងសង់



ដោយមានការសហការណ៍ល្អរវាងមន្រ្តីសង្គមកិច្ចផ្នែកសុខមាលភាពកុមារខេត្តកំពង់ចាម និង **អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម** គម្រោងបានធ្វើការជួសជុល និងកែលំអអាគារមួយចំនួនដូចជា អាគារស្នាក់នៅសម្រាប់ក្មេងស្រី និង ក្មេងប្រុស អាហារដ្ឋាន របងខ័ណ្ឌចែកជាពីររវាងមណ្ឌល និងការិយាល័យកណ្តាល ដាក់វាំងននតាមបង្អួច ដាក់គ្រែគេង ប្រព័ន្ធចំរុះទឹកស្អាត បន្ទប់ប្រឹក្សាយោបល់ បំពាក់បំពងពន្លត់អគីសភ័យថ្មី ប្រព័ន្ធទឹកភ្លើង ទូរដាក់ខោអាវរបស់សិស្សានុសិស្ស កីឡាស្ថាន ដាក់ឈ្មោះតាមអាគារ និងបន្ទប់និមួយៗ និងហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗ ទៀនៅក្នុងបរិវេណ មណ្ឌលបានបញ្ចប់រួចរាល់ហើយនោះ អង្គការនៅតែមាន គម្រោងសាងសង់ និងជួលជុលបន្តរហូត ទៅតាមលទ្ធភាព។ ដោយឡែកនៅឆ្នាំ ២០១៩នេះផងដែរ គម្រោងបានរៀបចំឲ្យមានសួនបន្លែតាមគ្រួសារនិមួយៗដើម្បីជាជំនួយទាំងស្មារតី និងកាយសម្បទាដើម្បីជាប្រយោជន៍ដល់សិស្សានុសិស្សដែលរស់នៅក្នុងមណ្ឌល។

## ខ- ផលិតផលសន្តិសុខស្បៀង និងការផ្តល់ជំនាញការចិញ្ចឹមជីវិតដល់សិស្ស



**-ការដាំបន្លែ៖** បន្លែគឺជាអាហារមួយដ៏សំខាន់សម្រាប់ទ្រទ្រង់ការរស់នៅក្នុងមណ្ឌល ដូច្នោះគម្រោងក៏បានពង្រីកទីធ្លាបន្លែមដោយប្រើប្រើកង់ឡានចាស់ៗធ្វើជាថ្នើដើម្បីឲ្យបន្លែលូតលាស់បានល្អម្យ៉ាងទៀត យើងធ្វើបែបនេះដើម្បីកាត់បន្ថយការទិញបន្លែពីផ្សារដែលមានតម្លៃខ្ពស់ សម្រាប់ឆ្នាំ២០១៩ សរុបបន្លែដែលដាំបានគិតជចំនួនសាច់ប្រាក់មានចំនួន២១៨ដូល្លាសហរដ្ឋអាមេរិក។ រហូតមកដល់ចុងឆ្នាំ យើងបានដាំស្វាយបន្ថែម ដាំចេក ដាំខ្នុរ និងរុក្ខជាតិហូបផ្លែមួយចំនួនទៀតនៅជុំវិញមណ្ឌលដើម្បីផ្គត់ផ្គងអាហារហូបចុកប្រចាំថ្ងៃរបស់សិស្សានុសិស្សដែលកំពុងសិក្សាជំនាញ។ ម្យ៉ាងទៀតនោះវាជាផ្នែកមួយនៃបំពេញបន្លែម និងការទ្រទ្រងការចិញ្ចឹមជីវិតប្រចាំថ្ងៃ របស់សិស្សមណ្ឌល និងការកាត់បន្ថយចំណាយការទិញម្ហូមប្រចាំថ្ងៃផងដែរ។

សរុបប្រចាំថ្ងៃ។ បន្លែមពីនេះទៀត ដាំមាន ត្រកួន កញ្ឆែត ហើយវារស់តាមបែបធម្មជាតិ មិនប្រើជាតិគីមី ដោយវាលូតលាស់តាមជីធម្មជាតិដែលនៅ ជុំវិញ មណ្ឌល ដំណាំនេះ ពួគប្រើប្រាស់ជារៀងរាល់ថ្ងៃពេលដែល សម្រាប់បំពេញតម្រូវការក្នុងខណៈពេល ម្ហូបទិញពីផ្សារមិនគ្រប់គ្រាន់។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ខ្វះបច្ចេកទេសក្នុងការដាំដុះ និងថែទាំ។<br>តម្រូវការបន្លែខ្ពស់ជារៀងរាល់ថ្ងៃ។ | ព្យាយាមសួរអ្នកជំនាញ និងដាំបែបដូនតា។<br>បង្កើនដីដាំដុះបន្ថែម។ |
| -ចំពោះបន្លែនៅតែមានសត្វល្អិតមកស៊ីបំផ្លាញបន្លែធម្មជាតិ<br>-ដីដែលកំពុងដាំបន្លែភាគច្រើនសម្បូរទៅដោយជាតិអាស៊ីត ធ្វើអោយបន្លែលូតលាស់យឺត។ | -បុគ្គលកគម្រោងនឹងបង្កើតជាតិពុលធម្មជាតិដើម្បីបណ្តេញសត្វទាំងនោះចេញ<br>-បុគ្គលិកជំនាញនឹងប្រើប្រាស់កំបោរកសិកម្មដើម្បីកាត់បន្ថយជាតិអាស៊ីត។ |

## ៦- សាលាថ្នាក់បម្រុងបន្ថែមនៅមណ្ឌលនៃក្តីញញឹម



ថ្នាក់ត្រៀមបានផ្តល់ជូនដល់សិស្សជំនាញជំនាន់ទីVII មុនពេលពួកគេបញ្ចប់ជំនាញនៅ ចុងឆមាសទី I ជាលក្ខណសិក្ខាសាលា និងបណ្តុះបណ្តាលដូចជា ផែនការអនាគតមុនចេញទៅរកមុខរបរ ផែនការទីផ្សារ របៀបចាប់ផ្តើអាជីវកម្មថ្មី និងរបៀបសរសេរបែបបទ ដើម្បីរកការងារធ្វើ។ នេះដើម្បីប្រាកដថា ពេលពួកគាត់ចេញពីមណ្ឌលបណ្តុះបណ្តាលទៅ ពួកគាត់ធ្វើការអ្វី នៅកន្លែងណា បានចំនួលប៉ុន្មាន។ ចំណែកជំនាន់ទី VIII ទើបតែជ្រើសរើសបានថ្មីអោយចូលរៀននៅក្នុងត្រីមាសទី| នៅខែមិនា ឆ្នាំ២០២០ ត្រូវបានផ្តល់ការសិក្សាចំណេះដឹងទូទៅ ដូចជា គណិតវិទ្យា ភាសាខ្មែរ ភាសាអង់គ្លេសមុនពួកគាត់ចាប់យកជំនា ហើយក្រៅពីនេះ កម្រោងផ្តល់វគ្គសិក្ខាសា ផែនការផ្សេងៗដូចមុនៗដែរ។ បន្ទាប់ពីពួកគាត់បានចប់ថ្នាក់ត្រៀម បុគ្គលិកគម្រោងបានធ្វើបទបង្ហាញមួយស្តីអំពី ការណែនាំតម្រង់ទិសដល់ពួកគាត់មុនពេលចាប់យកដជំនាញ។ ដោយឡែក ឆ្នាំ២០១៩ នេះ សិស្សជំនាញដែលមានចំនួន ២៤នាក់ សិស្សជាត់មុខមានចំនួន៤នាក់ កាត់សក់បុរស ១នាក់ ជួសជុលម៉ាស៊ីនត្រជាក់ ៣នាក់ កាំមេរា ៣នាក់ ជួសជុលម៉ូតូ ៥នាក់ បដិសណ្ឋារកិច្ចផ្នែកចុងភៅ ៨នាក់ ស្រីមានចំនួន៧នាក់ សិស្សទាំងអស់ត្រូវបានគម្រោងបញ្ជូនឲ្យទៅរៀននៅខាងក្រៅលើកលែងតែជំនាញមេកានិចផ្នែកជួសជុលម៉ូតូ និងសណ្ឋាគារ និងបដិសណ្ឋារកិច្ចតែប៉ុន្នោះដែលគម្រោងមានគ្រូប្រចាំការក្នុងមណ្ឌល។

## ៧- កម្មវិធីថែទាំសុខភាពបឋមនៅមណ្ឌលកុមារ

សិស្សទាំង ២៤នាក់ ស្រី១១នាក់មានការមើលថែទាំពីអ្នកគ្រូពេទ្យជាប្រចាំក្នុងមណ្ឌល។ ២៤នាក់ស្រី ១១នាក់ ទទួលបានការចាក់ វ៉ាក់សាំងការពារតេតាណុះ ក្នុងនោះផងដែរមានសិស្សចំនួន១១នាក់ស្រី៥នាក់មានផ្ទុកមេរោគជំងឺអេដស៍ទទួលបានការថែទាំដោយយកចិត្តទុកដាក់ និងប្រុងប្រយត្ន័។ សម្រាប់សិស្សដែលមានជម្ងឺធ្ងន់ធ្ងរ អង្គការនឹងបញ្ជូនទៅមន្ទីរពេទ្យខេត្តដើម្បីជួយព្យាបាលដោយឥតគិតថ្លៃ និងមានការសហការយ៉ាងល្អ។ ក្រៅពីនេះទៀត ពួកគាត់ត្រូវបានផ្តល់ការព្យាបាលផ្សេង ដូចជាត្រួតពិនិត្យនិងព្យាបាលសំអាត ធ្មេញដោយក្រុមគ្រូពេទ្យស្មគ្រ័ចិត្តរបស់សាលាគិលានុប្បដ្ឋាកខេត្តកំពង់ចាម កុំឡុងពេល

និស្សិតចុះកម្មសិក្សា។ ជាលទ្ធផល សិស្សទាំងអស់ទទួលបានសុខភាពល្អប្រសើរជាងមុន បើធៀបទៅនឹងកាលពីនៅឯសហាគមន៍ របស់ពួកគាត់។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
| --- | --- |
| ខ្វះជំនាញផ្តល់ប្រឹក្សាយោបល់ | គម្រោងនឹងផ្តល់ជំនាញនេះបន្ថែមដល់បុគ្គលិក |

## ៨-កម្មវិធី ណែនាំបន្ត

គិតពីចាប់ផ្តើមរហូតមកដល់ឆ្នាំ ២០១៧ សិស្សដែលបានរៀនចប់ជំនាញ ក្នុងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មាន៣ជំនាន់ សរុប ចំនួន ៨៦នាក់ សិស្សស្រីមានចំនួន២៩នាក់ ជាក់ស្តែងនៅឆ្នាំ២០១៩ សិស្សដែលបានបញ្ចប់ដោយជោគជ័យមានចំនួនសរុប២៤នាក់ (ស្រីសរុប៨នាក់) ជំនាញសណ្ឋាគារ និងបដិសណ្ឋារកិច្ច ផ្នែកចុងភៅមានចំនួន២០.៨៣% ផ្នែកសណ្ឋាគារ មានចំនួន៤.១៦ % ផាត់មុខមានចំនួន២០.៨៣% កាត់សក់បុរស




មានចំនួន៤.១៦% មេកានិចជំនាញជួសជុលម៉ូតូមានចំនួន១៦.១៦% ជួសជុលឡានមានចំនួន៤.១៦% អេឡិចត្រូនិចជំនាញជួសជុលម៉ាស៊ីនត្រជាក់មានចំនួន២០.៨៣% ជំនាញតបណ្តាញកាំមេរាសុវត្ថិភាពមានចំនួន១២.៥០% ពួកគាត់ទាំងនោះបានយកជំនាញទៅប្រើប្រាស់ផ្សេងៗគ្នា។ ក្នុងចំណោមសិស្សដែលបានបញ្ចប់វគ្គទាំងអស់ដែលពួកគាត់មានការធ្វើទាក់ទងនឹងមុខជំនាញដែលខ្លួនបានរៀនមានចំនួន៩១.៦៦% ធ្វើការខុសពីជំនាញដែលបានរៀនចប់៨.៣៣%ទៀតបានយកចំណេះដឹងនិងជំនាញយកទៅប្រើប្រាស់បើកអាជីវកម្មខ្លួនឯងនៅតាមសហាគមន៍ និងទីផ្សារដែលពួកគាត់បានតាំងនៅ និង%ជាសិស្សរៀនចប់ជំនាញហើយអត់ការងារធ្វើ នៅតែផ្ទះរកប្រាក់ចំណូលតាមរដូវការនៃការងារកសិកម្ម។

## ២.១.២. គម្រោងការអប់រំជាមូលដ្ឋាន (Basic Education Project)

| | |
| --- | --- |
| ក. គោលបំណង | ៖ ពង្រឹងការអប់រំនូវមូលដ្ឋានកំរិតបឋម |
| ខ. ចំនួនបុគ្គលិកសរុប | ៖ ៤ នាក់ ស្រី ១ នាក់ |
| គ. ទីតាំងគម្រោង | ៖ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តកោះកុង |
| ឃ. សរុបថវិកាគម្រោង | ៖ ៨៩,៣២៨.០០ ដុល្លា |
| ង. កាលបរិច្ឆេទគម្រោង | ៖ ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩ |

ច. សកម្មភាពអនុវត្តគម្រោង៖

## ១. អ្នកទទួលផលសរុប ៖

| អ្នកទទួលផលសរុប | អាយុក្រោម១៨ | | អាយុលើ១៨ | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| សិស្ស | ៣៨៥៤, | ១៦៧៨, | 0 | 0 |
| ក្លឹបកុមារយុវជន/ | 0 | 0 | 0 | 0 |
| អាជ្ញាធរដែនដី | 0 | 0 | ១៨២ | ៧៥ |
| ដៃគូអប់រំ | 0 | 0 | ១៨៦ | ៩៨ |
| សរុប៖ | ៣៨៥៤, | ១៦៧៨, | ២៨៨ | ១៧៣ |

## ២. លទ្ធផលដែលសម្រេចបាន៖

- **សកម្មភាពទី១៖** បណ្តុះបណ្តាលគណៈកម្មការទ្រទ្រង់សាលា គ្រូបង្រៀន និងកុមារស្តីពីការផលិតសម្ភារៈបង្រៀន និង រៀន
  - បានអនុវត្ត ចំនួន ៤ សាលា មាន ៖
    1) សាលា តាលោ អូរតាប៉ោង(ស្រុកបាកាន)
    2) សាលាស្ទឹងថ្មី (ស្រុកវាលវែង)
    3) សាលាព្រៃក១ (ស្រុកភ្នំក្រវាញ)។
    4) ក្នុងនោះមាននាយក/នាយិកា និង គ្រូថ្នាក់ទី១ដល់ទី៣ សរុប ២៥ នាក់ ស្រី ១២ មន្ត្រីការិយាល័យ ៣នាក់ ស្រី0 មន្ទីរអេយក ២ ស្រី១ មាតាបិតាសិស្ស ២៧ នាក់ស្រី១៨ សិស្ស ៥៥៨ នាក់ស្រី២៣៤ នាក់ ។
- **សកម្មភាព ទី២** ផ្តល់សៀវភៅអំណានផ្សេងៗ និងល្បែងអំណានសម្រាប់ថ្នាក់ទី ១ និងទី ៣
  - បានផ្តល់ចំនួន ១ សាលា គឺសាលា បឋមសិក្សាស្ទឹងថ្មី សម្រាប់ទិញរឿងនិទានចំរុះ និងសម្ភារដាក់កន្លែងអានក្នុងសហគមន៍ សរុបថវិកាបដិភាគ ចំនួន ៥0 ដុល្លា ។
- **សកម្មភាពទី៣** បណ្តុះបណ្តាលគ្រូបង្រៀនស្តីពី ការបង្រៀនអក្សរ និងលេខ ថ្នាក់ទី១ ដល់ទី ៣ ការរៀបចំតេស្តវាយតម្លៃការសិក្សារបស់កុមារ និងបំប៉នសិស្សរៀនយឺត នៅសាលាចំនួន១0 ក្នុងគោលដៅ។
  - បានអនុវត្ត ចំនួន ១0 សាលាគឺ៖
    1) មកពីស្រុកបាកាន ៤ សាលា (សាលាបឋមសិក្សា អូរតាប៉ោង ខ្នារទទឹង កោះវត្ត តាលោ)
    2) ស្រុកភ្នំក្រវាញ ៣ សាលា (សាលាបឋមសិក្សា ព្រងឹល លាច និង កោះចម្លង )
    3) ស្រុកវាលវែង៣ សាលា (សាលាបឋមសិក្សា ដូននាគ ស្ទឹងថ្មី និង អន្លង់រាប)
    4) ក្នុងនោះមាននាយក/នាយិកា និង គ្រូថ្នាក់ទី១ដល់ទី៣ សរុប ៦៨ នាក់ ស្រី ៤0នាក់ មន្ត្រីការិយាលយ៍ ១៨ នាក់ ស្រី ៣ នាក់ មន្ទីរអេយក ១៥ នាក់ ស្រី២ នាក់។

- **សកម្មភាពទី៤** ប្រជុំបង្កើនការយល់ដឹងដល់នាយកសាលាគណៈកម្មការទ្រទ្រង់សាលា គ្រូបង្រៀន និងសិស្សានុសិស្សលើគោលការណ៍ និងស្តង់ដារគុណភាពរបស់ QLE និង បោះពុម្ពជាបដាផ្សេងៗ។
  - បានអនុវត្ត ចំនួន ១០ សាលា
    1) មកពីស្រុកបាកាន៤ សាលា
    2) ស្រុកភ្នំក្រវាញ៣សាលា
    3) ស្រុកវាលវែង ៣ សាលា
    4) ក្នុងនោះមាននាយក/នាយិកា ១៧ ស្រី ២ នាក់ និង គ្រូបង្រៀន សរុប ៦៨នាក់ ស្រី៤០ នាក់ មន្ត្រីការិយាលយ័ ១៨ នាក់ ស្រី ២នាក់ មន្ទីរអេយក ១៣ នាក់ ស្រី១នាក់ មាតាបិតាសហាគមន៍ ៦៥ នាក់ ស្រី ៤៨ នាក់ គណៈទ្រទ្រង់សាលា ៩៣ ស្រី ៣១ នាក់ ក្រុមប្រឹក្សាកុមារ សរុប ១៤២នាក់ ស្រី ៧៥ នាក់ ។
- **សកម្មភាពទី៥** វាយតម្លៃផែនការរីកចម្រើនរបស់សាលារៀន ២ ដងក្នុង ១ ឆ្នាំ ដោយប្រើឧបករណ៍ QLE
  - បានអនុវត្ត ចំនួន ១០ សាលា
    1) មកពីស្រុកបាកាន ៤ សាលា
    2) ស្រុកភ្នំក្រវាញ ៣ សាលា
    3) ស្រុកវាលវែង ៣ សាលា
    4) ក្នុងនោះមាននាយក/នាយិកា និង គ្រូបង្រៀន សរុប ៤២ នាក់ ស្រី ២៤ មន្ត្រីការិយា ល័យ ០៥ នាក់ ស្រី០១នាក់ មន្ទីរអេយក ៣នាក់ ស្រី0នាក់ មាតាបិតាសហគមន៍ ១៥ នាក់។
- **សកម្មភាពទី៦** បង្កើតគាំទ្រនិងបណ្តុះបណ្តាល និង បង្កើតថ្នាក់គម្រូ សម្រាប់សិស្សពិការ
  - បានអនុវត្ត ចំនួនពីរសាលា គឺ
    1) សាលា បឋមសិក្សា ព្រងឹល (ស្រុកភ្នំក្រវាញ)
    2) និង សាលាកោះចម្លង (ស្រុកភ្នំក្រវាញ)
- **សកម្មភាពទី ៧** គាំទ្រដល់គណៈកម្មការគ្រប់គ្រងសាលាក្នុងការធ្វើបច្ចុប្បន្នភាពផែនទីខ្នងផ្ទះប្រចាំឆ្នាំសិក្សា២០១៨ និង ២០១៩។
  - ជួយសាលាបឋមសិក្សា ១០ គឺ សាលាអូរតាប៉ោង ខ្នារទទឹង កោះវត្ត តាលោ ព្រងឹល លាច កោះចម្លង ដូននាគ ស្ទឹងថ្មី និង អន្លង់រាប ។ អ្នកចូលរួមមាន លោកគ្រូ អ្នកគ្រូ ៦៨ នាក់ ស្រី ៤០ នាក់ មាតាបិតាសិស្ស ៦៤ស្រី ៤៨នាក់ គណៈទ្រទ្រង់សាលា ៩៣ ស្រី ៣១ក្រុមប្រឹក្សាកុមារ ១៤២ ស្រី ៧៥ នាក់ មន្ត្រី ការិ ស្រុក ១៨ នាក់ ស្រី ៣ នាក់ ។
- **សកម្មភាពទី ៨** ផ្តល់វគ្គបំប៉នដល់នាយករង និង ក្រុមប្រឹក្សាកុមារ ដើម្បីពង្រឹង និង រំលឹកពីតួនាទី និងភារៈកិច្ចរបស់ក្រុមប្រឹក្សាកុមារ ចំនួន ១០ សាលាគោលដៅ ដែលមានការសម្របសម្រួលពីមន្ត្រី

ការិយល័យស្រុក បាកាន ភ្នំក្រវាញ និង វាលវែង ចំនួន ៦ នាក់ស្រី ០ នាក់ និង អ្នកចូលរួមមាន នាយករង ចំនួន ១០ នាក់ ស្រី ១ នាក់ និង ក្រុមប្រឹក្សា កុមារចំនួន ១៤២ នាក់ ស្រី៧៥ នាក់ ។

- សកម្មភាពទី ៩ ផ្តល់ការគាំទ្រ លើបង្កើតតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី១ដល់ទី៦ ក្នុងសាលាគោលដៅទាំង១០ ក្នុងការិយាល័យស្រុក បាកាន វាលវែង និងភ្នំក្រវាញ ដែលមានមន្រ្តី មន្ទីរអប់រំខេត្ត ០៣ នាក់ ស្រី០ នាក់មន្រ្តី ការិយាល័យបឋម ចំនួន ៨ នាក់ ស្រី ១០ នាក់ មន្រ្តីការិ. ស្រុក សរុប ០៨ នាក់ ស្រី ០១ នាក់ លោកគ្រូ អ្នកគ្រូ ចំនួន ៦៨ នាក់ស្រី ៤០ នាក់ នាយក/នាយិកា ១៤ ស្រី ០១ នាក់ និង សិស្សថ្នាក់ទី១ ដល់ ទី៦ ចំនួន ៣៨៤៤ នាក់ ស្រី ១៩៤៦ នាក់។
- សកម្មភាពទី ១០ ផ្តល់វគ្គបំប៉នស្តីពី ការបញ្ចូលទិន្នន័យពិន្ទុតេស្តសិស្សទៅក្នុងប្រពន្ធ័ Computer ដល់ នាយក/នាយករង និង លោកគ្រូ អ្នកគ្រូ ចំនួន៤០ នាក់ ស្រី ៥នាក់ មន្រ្តី ការិ.ស្រុក ចំនួន ១២នាក់ ស្រី ២ នាក់។
- សកម្មភាពទី ១១ ផ្តល់វគ្គបំប៉នស្តីពីការស្វែងរកកុមារមានបញ្ហាពិការភាព ដល់លោកគ្រូអ្នកគ្រូ ចំនួន ៧ សាលា គោលដៅ (សាលាបឋមសិក្សា ព្រងឹល លាច កោះចម្លង អូរតាប៉ោង ខ្នារទទឹង តាលោ និង កោះវត្ត ដែលមានលោកគ្រូ អ្នកគ្រូ សរុប ៤៥ នាក់ ស្រី ២១ នាក់ មន្រ្តីការិ.ស្រុក ៨ នាក់ ស្រី ១ នាក់ ។
- សកម្មភាពទី១២ បានផ្តល់ថវិកា កាត់វ៉ែនតា ជូនកុមារមានបញ្ហាពិបាកក្នុងការមើល ចំនួន១ នាក់ នៅ សាលាបឋមសិក្សាព្រងឹល ថវិកាចំនួន៣០ ដុល្លា ។
- សកម្មភាពទី១៣ ផ្តល់វគ្គបំប៉នស្តីពី ការរៀបចំ និង បង្កើត ក្រុមការងារបច្ចេកទេសកម្រិតសាលា ចំនួន ១០ សាលា ។
- សកម្មភាពទី ១៤ គាំទ្រដល់នាយក/នាយិកាសាលាចំនួន៤ សាលានៅស្រុកបាកាន ចូលរួមទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ នៅសាលាបឋមសិក្សា ភូមិអូរ ស្រុកបាកាន ខេត្តពោធិសាត់ ។
- សកម្មភាពទី ១៥ គាំទ្រដល់នាយក/នាយិកា លើការងាររៀបចំផែនការប្រតិបត្តិសាលារៀន ចំនួន១០ សាលាបឋមសិក្សា។
- សកម្មភាពទី ១៦ គាំទ្រមន្ទីរអប់រំ យុវជន និងកីឡា អនុវត្តការគ្រប់គ្រងផ្អែកលើលទ្ធផល (SBM) នៅ សាលាបឋមសិក្សាភូមិអូរ ។

## ២.១.៤ គម្រោងអប់រំអនាគតកុមារ (Child's Future Education Project)

*ក. គោលបំណង* ៖ ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការរៀនសូត្រ និងជំនាញជីវិតរបស់កុមារនៅក្នុងការអប់រំមូលដ្ឋាន

*ខ. ចំនួនបុគ្គលិកសរុប* ៖ ៤ នាក់ ស្រី ២ នាក់

*គ. ទីតាំងគម្រោង* ៖ ខេត្តពោធិ៍សាត់

*ឃ. សរុបថវិកាគម្រោង* ៖ ៦១ ១៩០.៩៩,ដុល្លា

*ង. កាលបរិច្ឆេទគម្រោង* ៖ ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩

*ច. សកម្មភាពអនុវត្តគម្រោង៖*

## ១. អ្នកទទួលផលសរុប

| អ្នកទទួលផលសរុប | អាយុក្រោម១៨ | | អាយុលើ១៨ | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| សិស្ស | ៤,៥១៨ | ២,២២៦ | 0 | 0 |
| ក្លឹបកុមារយុវជន/ | ៤,៧២ | ២៥៧ | ៩ | ២ |
| អជ្ញាធរដែនដី | 0 | 0 | ៣០ | ៧ |
| ដៃគូអប់រំ | 0 | 0 | ១៤០ | ៥៨ |
| Total | ៤,៩៩០ | ២,៤៨៣ | ២៧៩ | ៦៧ |

## ២.លទ្ធផលដែលសម្រេចបាន៖

- **សកម្មភាពទី១៖** គាំទ្រក្រុមបំប៉ន និងពិនិត្យតាមដាន នៃការិយាល័យអប់រំយុវជន និងកីឡាស្រុក ដើម្បីធ្វើការតាមដាន និងវាយតម្លៃលើការងាររបស់សាលារៀនចំនួន១៩សាលាគោលដៅ (៦សាលានៅស្រុកភ្នំក្រវាញ ៤សាលា នៅស្រុកតាលោសែនជ័យ និង៩សាលានៅស្រុកបាកាន)។
  - គាំទ្រក្រុមបំប៉ន និងពិនិត្យតាមដាន នៃការិយាល័យអប់រំយុវជន និងកីឡាស្រុកភ្នំក្រវាញ និងស្រុកបាកានចុះតាមដានលើការបង្រៀន និងរៀន សាលាគោលដៅទាំង ១៩នៅស្រុកបាកាន និងភ្នំក្រវាញដូចជា សាលាបឋមអូរហោង វាល សំពោង វាលនិន្ទ្រា អង្គ្រង តាសាស់ បឹងព្រះពន្លៃ រវាង កោះស្វាយ ផ្ទះរុង និងបាកាន ភូមិអូរ ព្រះអំពិល បត់ត្រាច របងរមាស ព្រៃស្វាយ វត្តជ្រៃ ព្រះម្លូ និងព្រៃផ្តៅ។
- **សកម្មភាពទី២៖** ពង្រឹងសមត្ថភាពមន្ត្រីអប់រំតាមសាលាគោលដៅ
  - ដឹកនាំគ្រូ នាយក/នាយិកា និងគ្រូបង្រៀនចំនួន ២៨នាក់មកពី ១៨សាលាធ្វើទស្សនៈកិច្ចសិក្សានៅសាលាបឋមសិក្សាភូមិអូរ លើការបង្រៀន ការគ្រប់គ្រង និងការចូលរួមរបស់ សហគមន៍ក្នុងសាលារៀន។
  - បណ្តុះបណ្តាលនាយក និងគ្រូបង្គោល ចំនួន ២៨នាក់ អំពីដំណើរការបញ្ចូលពិន្ទុ និងការការវិភាគពិន្ទុសិស្សតាមកម្មវិធី Excel ។
  - គាំទ្រមន្ទីរអប់រំយុវជន និងកីឡាខេត្តពោធិ៍សាត់លើការបណ្តុះបណ្តាលលើលំហូរនៃការបង្រៀនភាសារខ្មែរ ដល់គ្រូបង្គោលចំនួន ១៤នាក់ មកពីសាលាបឋមសិក្សាភូមិអូរ ព្រៃផ្តៅ ព្រះម្លូរ អូរហោង កោះស្វាយ និងអង្គ្រង។
- **សកម្មភាពទី៣៖** គាំទ្រការប្រជុំ រវាង ក្រុមបច្ចេកទេស ការិយាល័យអប់រំយុជន និងកីឡាស្រុក នាយកសាលា និងប្រធានក្រុមបច្ចេកទេសថ្នាក់រៀន ដើម្បីពិនិត្យលើការបន្សីសៀវភៅ កម្មវិធីសិក្សាលម្អិត សៀវភៅសិក្សាគោល និង សៀវភៅស្តង់ដារអំណាន(ថ្នាក់ទី១-៣)ចំនួន១៩សាលាគោលដៅ។
  - គាំទ្រការិយាល័យអប់រំយុវជន និងកីឡាស្រុកបាកាន និងស្រុកភ្នំក្រវាញ បណ្តុះបណ្តាលគ្រូថ្នាក់ទី១ ដល់ទី៣ចំនួន ៤០នាក់ អំពីការបន្សីសៀវភៅស្តង់ដារអំណាន សិក្សាគោល និងសិក្សាលំអិត មកពី១៩សាលាគោលដៅ។

- គាំទ្រការប្រជុំកំរងចំនួន១លើក ចំនួន ៦កំរង (ស្រុកបាកានៈ កំរងដូងជ្រុំ និងកំរង បឹងខ្នារ ស្រុកភ្នំក្រវាញៈ កំរងតាសាស់ កំរងព្រៃក ១ កំរងសំរោង និង បត់រំដួល)

➢ សកម្មភាពទី៤ៈ គាំទ្រការការរៀបចំរចនាសម្ព័ន និងបណ្តុះបណ្តាល ក្រុមប្រឹក្សាកុមារ នៅសាលាគោលដៅទាំង១៩

- សហការជាមួយនាយកសាលាទាំង១៩សាលាគោលដៅ បង្កើតក្រុមប្រឹក្សាកុមារបាន១៩ក្រុម
- សហការជាមួយនាយកសាលា និងការិយាល័យអប់រំស្រុកបាកាន និងភ្នំក្រវាញ ចុះបណ្តុះបណ្តាលក្រុមប្រឹក្សាកុមានចំនួន១៩សាលាដែលមានកុមារចូលរួម ២០៩នាក់
- សហការមួយនាយលសាលា លោកគ្រូអ្នកគ្រូចំនួន១៩សាលាពង្រឹងការអនុវត្តការងាររបស់ក្រុមប្រឹក្សាកុមារ

➢ សកម្មភាពទី៥ៈ សហការជាមួយនាយកសាលា និងគ្រូបង្រៀន ដើម្បីជ្រើសរើស និងបណ្តុះបណ្តាលមិត្តអប់រំមិត្ត នៅ ១៩សាលាគោលដៅ (ការបណ្តុះបណ្តាលផ្តោតទៅលើ តួនាទី និងទំនួលខុសត្រូវ ការធ្វើផែនការ ការសម្របសម្រួល កិច្ចតែងការបង្រៀន និងការរៀបចំថ្នាក់រៀន)

- សការជាមួយនាយកសាលាជ្រើសរើសមិត្តអប់រំមិត្ត ៩០នាក់ថ្នាក់ទី៤-៦ចំនួន១៩សាលានៅស្រុកបាកាន និងភ្នំក្រវាញពីការធ្វើផែនការជួយសិស្សខ្សោយ និងការសរសេរគ្រោងផែនការបង្រៀន
- សហការជាមួយការិយាល័យអយក ស្រុកបាកាន និងស្រុកភ្នំក្រវាញ និងនាយកសាលា ១៩ បណ្តុះ មិត្តអប់រំមិត្ត ចំនួន៩០នាក់

➢ សកម្មភាពទី៦ៈ នៅកំឡុងពេលវិសមកាល សម្របសសម្រួលគ្រូបង្រៀន អោយធ្វើការជាមួយក្រុមមិត្តអប់រំមិត្ត ដើម្បីអោយបង្រៀន សិស្សរៀនយឺត

- សហការជាមួយការិយាល័យអយក. ស្រុកបាកាន និងស្រុកភ្នំក្រវាញ ប្រជុំជាមួយនាយកសាលានិងគណកម្មធិការទ្រទ្រង់សាលា ទាំង១៩អំពីការបណ្តុះបណ្តាលសិស្សរៀនយឺតនៅវិសមកាល
- ឧបត្ថម្ភគ្រូបង្រៀនសិស្សរៀនយឺតចំនួន ២២ថ្នាក់នៅសាលាគោលដៅទាំង១១សាលា ដូចជា អង្គ្រង កោះស្វាយ ផ្ទះរុង និងបាកាន ភូមិអូរ ព្រះអំពិល របងរមាស ព្រៃស្វាយ វត្តជ្រៃ ព្រះម្លូ និងព្រៃផ្តៅ ដែលមានសិស្សរៀនយឺត ២៣៧នាក់

➢ សកម្មភាពទី៧ៈ សហការជាមួយការិយាល័យអប់រំស្រុកបាកាន និងភ្នំក្រវាញ ដើម្បីបង្រៀនអំពីរបៀបធ្វើតេស្តបុរេគណិត និងភាសាខ្មែរទៅគ្រូសាលាគោលដៅទាំង១៩

- ដឹកនាំការបណ្តុះបណ្តាលពីរបៀបធ្វើតេស្តបុរេគណិត និងភាសាខ្មែរដែលមានអ្នកចូលរួម ១៣នាក់ (មន្ទីរអប់រំយុវជន និងកីឡា ៣នាក់ និងការិយាល័យអប់រំយុវជន និងកីឡាស្រុក បាកាន និងភ្នំក្រវាញ ១០នាក់) នៅខេត្តពោធិ៍សាត់
- គាំទ្រការិយាល័យអប់រំយុវជន និងកីឡាស្រុកបាកាន និងភ្នំក្រវាញ ក្នុងការបណ្តុះបណ្តាលការបង្កើតតេស្ត និងការធ្វើតេស្ត បុរេគណិត និងភាសាខ្មែរទៅគ្រូ ៤៦នាក់ មកពី ១៩សាលាគោលដៅ។

- **សកម្មភាពទី៨៖** គាំទ្រមន្ទីរអប់រំយុវជន និងកីឡាខេត្ត និងការិយាល័យអប់រំយុវជន និងកីឡាស្រុកបាកាន និងភ្នំក្រវាញ និងយកសាលា និងគ្រូបង្រៀន ធ្វើតេស្តបុរេគណិត និងភាសាខ្មែរ លើសិស្សសាលាគោលដៅទាំង១៩
  - សហការជាមួយមន្ទីរអេយក និង ការិអេយក ធ្វើតេស្តដើមឆ្នាំ និងចុងឆ្នាំបុរេគណិត និងភាសាខ្មែរសិស្សថ្នាក់ទី ៣ និងទី៦ នៃសាលាគោលដៅចំនួន១០ ដែលមានសិស្សសរុប ២៥៩
- **សកម្មភាពទី៩៖** ផ្តល់សម្ភារៈ និងបង្កើតថ្នាក់គម្រូដល់សាលាគោលដៅ
  - ផ្តល់សម្ភារៈតុបតែងសាលារៀន និងបង្កើតថ្នាក់គម្រូដល់សាលាភូមិអូរ និងសាលាព្រះម្លូ
- **សកម្មភាពទី១០៖** សម្របសម្រួលការពិភាក្សារវាងគណៈកម្មការទ្រទ្រង់សាលា និង ការិយាល័យអប់រំយុវជន និងកីឡាស្រុកបាកាន និងស្រុកភ្នំក្រវាញ
  - គាំទ្រការិយាល័យអប់រំយយវជន និងកីឡាស្រុកភ្នំក្រវាញ និងបាកាន រៀបចំរចនាសម្ព័នគណកម្មាធិការទ្រទ្រង់សាលាចំនួន១៩សាលា ដូចជា អូរហេង វាល សំរោង វាលនិន្ទ្រា អង្គ្រងតាសាស់ បឹងព្រះពន្លៃ ព្រហស្ពក្បាល រវាង កោះស្វាយ ផ្ទះរុង និងបាកាន ភូមិអូរ ព្រះអំពិលបត់ត្រាច របងរមាស របងរមាស១ ព្រៃស្វាយ រត្តជ្រៃ ព្រះម្លូ និងព្រៃផ្តៅ។
  - គាំទ្រការិយាល័យអប់រំយុវជន និងកីឡាស្រុកភ្នំក្រវាញ និងបាកាន ប្រជុំជាមួយគណៈកម្ម ការទ្រទ្រង់សាលាចំនួន១៩សាលាអំពីការអភិវឌ្ឍន៍សាលា
- **សកម្មភាពទី១១៖** គាំទ្រកុមារចូលរួមប្រជុំផែនការវិនិយោគឃុំដើម្បីផ្សាភ្ជាប់មាតាបិតា តំណាង ក្លិបយុវជន និងសហគមន៍មូល ដ្ឋាន ក្នុងការធ្វើផែនការការសម្រេចចិត្ត និងសកម្មភាពផលជះ លើការអភិវឌ្ឍសាលារៀន និងការអនុវត្តសាលាកុមាមេត្រី
  - បញ្ជូនប្រធានក្លិបកុមារ ចំនួន ១០នាក់ចូលរួមកម្មវិធីសមាហរណកម្មកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឃុំសង្កាត់ នៅស្រុកភ្នំក្រវាញ ស្រុកតាលោសែនជ័យ និងស្រុកបាកាន
  - សម្របសម្រួលក្លិបកុមារប្រចាំឃុំ សំរោង ផ្ទះរុង បឹងខ្នា និងបឹងបត់កណ្តោល ស្នើរបញ្ហាកុមារដាក់បញ្ចូលបញ្ហាកុមារចំនួន ១៧ បញ្ហា ក្នុងផែនការវិនិយោគឃុំ ឆ្នាំ២០២០
- **សកម្មភាពទី១២៖** រៀបចំសិក្ខាសាលាឆ្លុះបញ្ជាំងការអនុវត្តគម្រោង និងផែនការបន្តឆ្នាំ ២០១៩-២០២០
  - រៀបចំសិក្ខាសាលាឆ្លុះបញ្ជាំងការអនុវត្តគម្រោង ចំនួន១ដង ដែលមានអ្នកចូលរួម ៧៧នាក់មកពីមន្ទីរអេយក ខេត្ត ការិអេយក ស្រុកបាកាន និងភ្នំក្រវាញ នាយកសាលា ប្រធានក្លឹបកុមារ ក្រុមប្រឹក្សាឃុំ បឹងខ្នា បឹងបត់កណ្តោល សំរោង និង ផ្ទះរុង
  - គាំទ្រកុមាររៀបចំសិក្ខាសាលាបង្ហាញលទ្ធផលការសិក្សាស្រាវជ្រាវស្ថានភាពសិទ្ធិកុមារនៅស្រុកបាកាន និងស្រុកភ្នំក្រវាញ ដែលមានអ្នកចូលរួមចំនួន ៨៧នាក់មកពីមកពីមន្ទីរអេយក ខេត្ត ការិ.អេយក ស្រុកបាកាន និងភ្នំក្រវាញ នាយកសាលា ប្រធានក្លឹបកុមារ ក្រុមប្រឹក្សាឃុំ បឹងខ្នា បឹងបត់កណ្តោល សំរោង និង ផ្ទះរុង ។
- **សកម្មភាពទី១៣៖** ផ្តល់វគ្គបណ្តុះបណ្តាល ប្រធានក្លិបយុវជន មកពី១៩ក្លិប

- សហការជាមួយគកនក បើកវគ្គបណ្តុះបណ្តាលចំនួន ៣លើក ដល់ប្រធាន អនុប្រធាន និង ហិរញ្ញឹក ក្រុមកុមារ/យុវជន អំពីរបៀបដឹកនាំប្រជុំ សរសេរបាយការណ៍ និង សំណើរសុំថវិការ ដល់កុមារ ៧៦ នាក់ មកពី១៩ភូមិ អូរហោង វាល សំរោង វាលនិន្ទ្រា អង្ក្រង តាសាស់ បឹងព្រះពន្លៃ រវាង កោះស្វាយ ផ្ទះរុង ភូមិអូរ ដូងជ្រុំ ព្រះអំពិល បត់ត្រាច និងរបងរមាស ព្រះម្លូ វត្តជ្រៃ ព្រៃផ្តៅ និងព្រៃស្វាយ ។

➢ **សកម្មភាពទី១៤៖** ផ្តល់សម្ភារដល់ក្លិបយុវជន ចំនួន១៩ក្លិប ដូចជា សៀវភៅរឿងនិទាន សម្ភារកីឡា និងសម្ភារបង្រៀនផ្សេងៗ

- ផ្តល់សសម្ភារកីឡា និងរឿងនិទានដល់ក្លិបកុមារចំនួន១៩ នៅ ឃុំ បឹងខ្នា និងឃុំបឹងបត់កណ្តោល ស្រុកបាកាន ឃុំសំរោង និង ឃុំផ្ទះរុង ស្រុកភ្នំក្រវាញ (បាល់ទាត់១៩ បាល់ទះ ១៩ តារាងបាល់ទះ១៩ សៀវភៅរឿងនិទានកុមារ១,២៩២ក្បាល)

➢ **សកម្មភាពទី១៥៖** គាំទ្រការប្រជុំប្រចាំត្រីមាសតំណាងក្លឹបយុវជន ចំនួន១៩ក្លិប

- គាំទ្រតំណាងក្លិបកុមារ/យុវជន ប្រចាំស្រុកបាកាន និងភ្នំក្រវាញ ចំនួន ២នាក់ចូលរួមប្រជុំបណ្តាញនៅខេត្តសៀមរៀបចំនួន ១លើក ដែលរៀបចំដោយ បណ្តាញអង្គការ
- គាំទ្រតំណាងកុមារ/យុវជន ១នាក់ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីកាពិនិត្យ និងប្រមូលធាតុចូលក្នុងរបាយការណ៍ពង្រាងនៃការអនុវត្តសិទ្ធកុមារនៅកម្ពុជា នៅក្រុងភ្នំពេញចំនួន១លើក ដែលរៀបចំដោយ បណ្តាញអង្គការ
- គាំទ្រដំណាងកុមារ/យុវជន ២នាក់ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រៀងលើរបាយការណ៍សិទ្ធិកុមារនៅខេត្តបាត់ដំបង ចំនួន១លើក ដែលរៀបចំដោយ បណ្តាញអង្គការកុមារកម្ពុជា ។

➢ **សកម្មភាពទី១៦៖** គាំទ្រការប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំរបស់ក្លិបយុវជនចំនួន១៩ក្លិប

- សហការណ៍ជាមួយកនកឃុំ សម្របសម្រួលក្លិបកុមារ/យុវជន ប្រជុំប្រចាំខែប្រមូលព័ត៌មានបញ្ហាកុមារ មួយខែម្តង ចំនួន ២២៨ប្រជុំ នៅភូមិ នៅភូមិ អូរហោង វាល សំរោង វាលនិន្ទ្រា អង្ក្រង តាសាស់ បឹងព្រះពន្លៃ រវាង កោះស្វាយ ផ្ទះរុង ភូមិអូរ ដូងជ្រុំ ព្រះអំពិល បត់ត្រាច របងរមាស វត្តជ្រៃ ដើមជ្រេស ព្រះម្លូ និង ព្រៃផ្តៅ
- គាំទ្រការប្រជុំប្រចាំត្រីមាសរបស់ក្លិបយុវជន ចំនួន ១៩ក្លិប
- គាំទ្រការប្រជុំប្រចាំត្រីមាសរបស់គកនកឃុំចំនួន ៤ ឃុំ (បឹងខ្នារ បឹងបត់កណ្តោល ផ្ទះរុង សំរោង)
- គាំទ្រក្លិបយុវជន ថវិការ ៣៨០០ ដុល្លា ក្នុងការជួយកុមារក្រីក្រ និងចាស់ជរា

➢ **សកម្មភាពទី១៧៖** សហការណ៍ជាមួយគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារដើម្បីគាំទ្រក្លឹបកុមារ/យុវជន ធ្វើការសិក្សាស្រាវជ្រាវលើបញ្ហាកុមារនៅឃុំគោលដៅទាំង៤

- ធ្វើការសិក្សាស្រាវជ្រាវលើបញ្ហាកុមារចំនួន៤ ឃុំ ផ្ទះរុង សំរោង បឹងខ្នា និងបឹងបត់កណ្តោល ដែលមានកុមារចូលរួម ១៩៥នាក់។
- ប្រជុំជាបូកសរុបរបាយការណ៍ដែលក្លិបកុមារ/យុវជន សិក្សាស្រាវជ្រាលើបញ្ហាកុមារចំនួន៤ឃុំ

- សម្របសម្រួលការពិគ្រោះយោបល់រវាងកុមារ និងជាមួយឃុំ ទាំង៩លើបញ្ហាដែលកុមាររកឃើញ ចំនួន៩លើក។

## ៣. បញ្ហាប្រឈម

- សាលាគោលដៅចំនួន ១៧ មិនទាន់មានបណ្ណាល័យ និង បណ្ណារក្ស ដាច់ដោយឡែដែលបម្រើអោយបង្កើនការសិក្សាស្រាវជ្រាវ និងការអានសៀវភៅ
- សិស្សនៅតំបន់ដាច់ស្រយាលមានអត្រាការបោះបង់ច្រើន
- សាលាបឋមសិក្សាដូននាគ អន្លង់រាប ខ្នារទទឹង លាច គណៈទ្រទ្រង់សាលាមិនសូវមានសកម្មភាពក្នុងការចូលរួមជួយក្នុងការអភិវឌ្ឍសាលា ក៏ដូចជាការងារ អប់រំក្នុងសាលា។
- សាលាបឋមសិក្សា អូរតាប៉ោង តាលោ ខ្នារទទឹង ដូននាគ អន្លង់រាប លាច ការគៀងគរ មាតាបិតាសិស្សអោយចូលរួមក្នុងការងារ ថ្នាក់រៀនរបស់កូនៗ មិនសូវមានដំណើរការ។
- លោកគ្រូអ្នកគ្រូ មួយចំនួន មិនបានយកវិធីសាស្រ្ត បង្រៀនដែលបានទទួលពីវគ្គបំប៉នទៅអនុវត្តក្នុងពេលបង្រៀន។

## ៤. ដំណោះស្រាយ

- សហការជាមួយការិយាល័យអប់រំយុវជន និងកីឡា រៀបចំរចនាសម្ព័ន គណកម្មាធិការទ្រទ្រង់សាលាថ្មី។
- សហការជាមួយនាយក/នាយិកា លោកគ្រូ/អ្នកគ្រូ រៀបចំបង្កើតគណៈកម្មការថ្នាក់រៀន ទីកន្លែង អាន និង សិក្សា នៅតាមផ្ទះ ក៏ដូចសហាគមន៍បន្ថែម។
- សហការជាមួយមន្ត្រី អយក ខេត្ត ស្រុក នាយក ចុះតាមដាន ពង្រឹងលើការបង្រៀនរបស់គ្រូលើវិធីសាស្រ្តបង្រៀន នៅតាមសាលា អោយបានទៀងទាត់ ។
- សហការជាមួយនាយក/នាយិកា លោកគ្រូ អ្នកគ្រូ រៀបចំបណ្ណាល័យជ្រុងទីចាត់ការ

## ៥. សំណូមពរ

- សុំអោយអាជ្ញាធរដែនដីមាតាបិតានិងដៃគូរពាក់ព័ន្ធយកចិត្តទុកដាក់ពីបញ្ហាកុមារនិងស្វែងរកដំណោះស្រាយរួមគ្នា
- សុំឱ្យមន្ត្រីរបស់មន្ទីរ និងការិយាល័យ អប់រំ យុវជននិងកីឡាស្រុក ចុះតាមដាននិងត្រួតពិនិត្យឱ្យបានទៀតទាត់ ដល់នាយក នាយិកាសាលា និងលោកគ្រូ អ្នកគ្រូ ដើម្បីគុណភាពរៀន និងបង្រៀនតាមថ្នាក់នីមួយៗ។
- សូមអោយក្រុមប្រឹក្សាឃុំដាក់បញ្ចូលរាល់បញ្ហានិងតម្រូវការរបស់កុមារចូលក្នុងកម្មវិធីវិនិយោគឃុំ

- សុំអោយអាជ្ញាធរដែនដីមាតាបិតានិងដៃគូរពាក់ពន្ធ័យកចិត្តទុកដាក់ពីបញ្ហាកុមារនិងស្វែងរក ដំណោះស្រាយរួមគ្នា
- សុំឱ្យមន្ត្រីរបស់មន្ទីរ និងការិយាល័យ អប់រំ យុវជននិងកីឡាស្រុក ចុះតាមដាននិងត្រួតពិនិត្យ ដល់នាយកសាលា និងលោកគ្រូ អ្នកគ្រូ ដើម្បីគុណភាពរៀន និងបង្រៀនតាមថ្នាក់នីមួយៗ ព្រមទាំងពង្រឹការគ្រប់គ្រង និងដឹកនាំរបស់នាយក នាយិកាសាលារៀន។
- សូមមន្ទីរអេយក ដាក់ពង្រាយគ្រូឱ្យគ្រប់នឹងនិយាមដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ៕

## ២.២-កម្មវិធីសុខភាព

### ២.២.១. គម្រោងផែនការគ្រួសារ (Family Planning Project)

*ក. គោលបំណង* ៖ ផ្តល់នៅចំណេះដឹងទៅដល់ក្រុមគោលដៅអោយយល់ដឹងពី មធ្យោបាយ ពន្យាកំណើតបែបទំនើប និងធ្វើអោយស្ត្រីមានការ ផ្លាស់ប្តូរឥរិយាបទ មកប្រើប្រាស់មធ្យាបាយពន្យាកំណើតបែប ទំនើប ប្រកបប្រសិតភាពខ្ពស់ ។

*ខ. ចំនួនបុគ្គលិកសរុប* ៖ ៩ នាក់ ស្រី៨ នាក់

*គ. ទីតាំងគម្រោង* ៖ ខេត្តកំពង់ចាម (៩ស្រុក និង១ក្រុង)

*ឃ. សរុបថវិកាគម្រោង* ៖ ៣៧,១៥៦.៤៩ ដុល្លា

*ង. កាលបរិច្ឆេទគម្រោង* ៖ ខែមករា ដល់ ខែវិច្ឆិការ ឆ្នាំ២០១៩

*ច. សកម្មភាពអនុវត្តគម្រោង៖*

- ធ្វើការចុះអប់រំមួយទល់មួយពីមធ្យោបាយពន្យារកំណើតទាំងប្រាំបែបទំនើបដល់ស្ត្រីក្រុមគោល ដៅសរុប ចំនួន ៨១៣ នាក់ នៅក្នុងឃុំចំនួន ៨២ឃុំ និងស្រុកចំនួន ០៩ ស្រុក និង ក្រុងចំនួន ០១ ដែលរួមមាន ស្រុកស្រីសន្ធរ ស្រុកកងមាស ស្រុកកោះសូទិន ស្រុកកំពង់សៀម ស្រុកបាធាយ ស្រុកចំការលើ ស្រុកជើងព្រៃ និងក្រុងកំពង់ចាម ដែលស្ថិតនៅក្នុងខេត្តកំពង់ចាម ។
- បានបញ្ជូនស្ត្រីគោលដៅជាពិសេសស្ត្រីក្រោយសំរាល ក្រោយរំលូត ស្ត្រីដែលមានកូនច្រើន ស្ត្រីមិនទាន់ប្រើ ស្ត្រីដែលប្រើធម្មជាតិ និងស្ត្រីកំពុងប្រើតែមិនទៀងទាត់សរុបចំនួន ៨៩៧ នាក់ ទៅទទួលការប្រឹក្សា និងប្រើប្រាស់មធ្យោបាយពន្យារកំណើត នៅតាមមណ្ឌលសុខភាព សាន់ក្លីនិក និងអ្នកផ្តល់សេវាដ៏ទៃទៀតដែលមានក្នុងសហគមន៍។
- បានអប់រំស្ត្រីគោលដៅជាពិសេសស្ត្រីក្រោយសំរាល ក្រោយរំលូត ស្ត្រីដែលមានកូនច្រើន ស្ត្រីមិនទាន់ប្រើ ស្ត្រីដែលប្រើធម្មជាតិ នឹងស្ត្រីកំពុងប្រើតែមិនទៀងទាត់សរុបចំនួន ១០,៥៦៨ នាក់ បានទទួលការប្រឹក្សាពីជំរើសនៃការមានផ្ទៃពោះ (រំលូតដោយសុវត្តិភាព) នៅតាមមណ្ឌលសុខភាព សាន់ក្លីនិក និងអ្នកផ្តល់សេវាដ៏ទៃទៀតដែលមានក្នុងសហគមន៍។
- បានចុះសួរសុខទុក្ខស្ត្រី ដែលបានប្រើសេវាកងដាក់ក្នុងស្បូនទាំងលើកទី១ចំនួន ៨៣០ នាក់ និងលើកទី២ ចំនួន ៦៩៣ នាក់។

- មន្ត្រីសំរបសំរួលគំរោងបានចុះសួរសុខទុក្ខស្ត្រី ដែលបានទទួលការអប់រំ ៩០ នាក់ និង ប្រើសេវាពន្យារកំណើតកងដាក់ក្នុងស្បូនចំនួន២២០នាក់ ដើម្បីត្រួតពិនិត្យលើគោលការណ៍ Tiahrt និងបញ្ជាក់ពីគុណភាពនៃទិន្នន័យ ដែលរាយការណ៍ដោយ បុគ្គលិកគំរោង។
- មន្ត្រីសំរបសំរួលគំរោងបាន ចុះពិនិត្យការងារបច្ចេកទេស និងពង្រឹងគុណភាពអប់រំរបស់បុគ្គលិកសហគមន៍សរុបចំនួន ៧០ដង ដើម្បីកែលំអ និងស្តាបនាគំរោងទាន់ពេលវេលា។
- នាយកអង្គការបានចុះពិនិត្យការងារ ផ្តល់បច្ចេកទេស និងពង្រឹងគុណភាពអប់រំរបស់បុគ្គលិកនៅតាមសហគមន៍ចំនួន ២ លើក ដើម្បីកែលំអនិងស្តាបនាគំរោងទាន់ពេលវេលា។
- បានផ្ទៀងផ្ទាត់ទិន្នន័យ ដែលបញ្ជូនដោគជ័យដោយ IPC និងមន្ត្រីសំរបសំរួលកម្មវិធីមុនផ្ញើជូនភី អេសយេ ជារៀងរាល់ខែ ។
- ធ្វើរបាយការណ៍រាល់ការចុះអភិបាលកិច្ចដោយមន្ត្រីសំរបសំរួលគំរោង
- រៀបចំប្រជុំប្រចាំសប្តាហ៍/ខែ រវាងបុគ្គលិក IPC និងថ្នាក់គ្រប់គ្រងដើម្បីពិនិត្យមើលលទ្ធផលការងារ ។
- រៀបចំប្រជុំអ្នកពាក់ព័ន្ធប្រចាំត្រីមាសជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា ស្ថាប័នសុខាភិបាលខេត្ត អាជ្ញាធរពាក់ព័ន្ធជាដើម ។
- សហការជាមួយក្រុមចល័តរបស់អង្គការ PSK ដើម្បីបញ្ជូនស្ត្រីទៅទទួលសេវានៅថ្ងៃមានព្រឹត្តិការណ៍ពិសេសសហការជាមួយអ្នកផ្តល់សេវាពន្យារកំណើតទាំងឯកជន និងសាធារណៈ ដើម្បីជំរុញអោយការផ្តល់សេវាដល់អតិថិជនកាន់តែប្រសើរ និងមានទំនុកចិត្តពីស្ត្រី បុគ្គលិកគំរោង បានចែកចាយសំភារៈអប់រំ ដល់ស្ត្រីគោលដៅក្នុងពេលអប់រំ និងការចុះសួរសុខស្ត្រីក្រោយសំរាលនិងក្រោយរំលូតក្រោយ ពីពួកគាត់បានចូលរួមពិភាក្សាលើកទីមួយពីជំរើសនៃមធ្យោ បាយពន្យារកំណើត។

## លទ្ធផលសំរេចបាន /Output

**១. ការទំនាក់ទំនងដើម្បីអោយមានការផ្លាស់ប្តូរទៅលើមធ្យោបាយពន្យារកំណើត (ការអប់រំ) Birth Spacing Behaviour Change Communication (Woman reached)**

### ១.១ ចំនួនស្ត្រីដែលទទួលបានការអប់រំ






## ១.២ ចំនួនស្ត្រីក្រោយសំរាល និងរំលូតដែលបានតាមដាន និងសួរសុខទុក្ខ

| ប្រភេទស្ត្រី | បានអប់រំប្រចាំឆ្នាំ | បានអប់រំលើកទី២ | បានអប់រំលើកទី៣ |
|---|---|---|---|
| ស្ត្រីក្រោយសំរាល(PP) | 3631 | 6142 | 787 |
| ស្ត្រីក្រោយរំលូត (PA) | 177 | 291 | 57 |

## ១.៣ ចំនួនស្ត្រីដែលបានទទួលការអប់រំពីជំរើសនៃការមានផ្ទៃពោះ*(Increase awareness and access to safe abortion service)*

| ប្រភេទស្ត្រី | Non-User | PP/new Mama | PA | Big Mama | TM | Inconsistence FP user | Total | លទ្ធផល (%) |
|---|---|---|---|---|---|---|---|---|
| ផែនការអប់រំត្រឹមាស | | | | | | | 7722 | |
| លទ្ធផលអប់រំ | 1485 | 3631 | 177 | 468 | 2229 | 2578 | 10,568 | 137 % |

## ១.៤ ចំនួនយុទ្ធនាការអប់រំបានអនុវត្ត

| ប្រភេទយុទ្ធនាការ | **MA event** | **Happy couple event** | សំគាល់ |
|---|---|---|---|
| ផែនការត្រីមាស | 2 | 2 | |
| ចំនួនយុទ្ធនាការបានធ្វើ | 5 | 2 | |
| ចំនួនអ្នកចូលរួម (បញ្ជាក់ចំនួនបុរសដែលបានចូលរួមយុទ្ធនាការនីមួយៗ) | 144 | 56 | |
| លទ្ធផលបញ្ជូនបាន (រៀបរាប់ប្រភេទសេវា) | 0 | 0 | |





## ២. ការបញ្ជូនស្ត្រីទៅទទួលការប្រឹក្សា និងប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើប Referral to Modern Birth Spacing Counselling and Services

## ២.១ លទ្ធផលនៃការបញ្ជូន




| សូចនាករ Indicators | ប្រភេទសេវា Type of BSM | អ្នកផ្តល់សេវា Type of Provider | ផែនការ Planning | លទ្ធផល Result | ខ្វះ/លើស Lack/Over | លទ្ធផល% Result % |
|---|---|---|---|---|---|---|
| លទ្ធផលបញ្ជូនជោគជ័យ ប្រចាំត្រីមាស | ម.រយៈពេលខ្លី (ថ្នាំចាក់, លេប និង ស្រោមអនាម័យ) | ក្លីនិកសាន់ | 75 | 76 | 1 | 135% |
| | | មណ្ឌលសុខភាព | 0 | 24 | 24 | 0% |
| | | ក្លីនិកផ្សេងៗ | 0 | 1 | 1 | 0% |
| | | សរុប | 75 | 101 | 26 | 135% |
| | កងដាក់ក្រោមស្បែក | ក្លីនិកសាន់ | 20 | 27 | 7 | 295% |
| | | មណ្ឌលសុខភាព | 0 | 21 | 21 | 0% |
| | | ក្លីនិកផ្សេងៗ | 0 | 11 | 11 | 0% |
| | | សរុប | 20 | 59 | 39 | 295% |
| | កងដាក់ក្នុងស្បូន | ក្លីនិកសាន់ | 1200 | 766 | 434 | 75% |
| | | មណ្ឌលសុខភាព | 0 | 116 | 116 | 0% |
| | | ក្លីនិកផ្សេងៗ | 0 | 15 | 15 | 0% |
| | | សរុប | 1200 | 897 | 565 | 75% |
| | សរុបរួម | | 1295 | 1057 | 650 | 82% |

## ២.២ ប្រភេទស្ត្រីដែលបានប្រើប្រាស់មធ្យោបាយពន្យារកំណើត




1- ការសួរសុខទុក្ខស្ត្រីក្រោយដាក់កងក្នុងស្បូន ( IUD user follow up )

| Follow up | មិនមានបំណងដក | មានបំណងដក | បានដកចេញ |
|---|---|---|---|
| # of 1st | 830 | 0 | 1 |
| # of 2nd | 693 | 4 | 0 |
| Total | 1523 | 4 | 1 |

3. ការប្រើប្រាស់និងចែកចាយសម្ភារៈ

| ល.រ | ប្រភេទសម្ភារៈ | ចំនួនទទួលពី PSI | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|---|---|
| ១ | អាវយឺតបុគ្គលិក | ៥១ | ១៧ | ១៦ | ១៨ | ០ |
| ២ | អាវក្រៅសម្រាប់បុគ្គលិក | ១០ | ១០ | ០ | ០ | ០ |
| ៣ | អាវពណ៌សដៃវែង | ០ | ០ | ០ | ០ | ០ |
| ៤ | អាវយឺតពណ៌លឿងសំរាប់អតិថិជន | ១០០ | ១០០ | ០ | ១០ | ០ |
| ៥ | ការបូបស្ពាយខៀវ | ១១ | ៩ | ០ | ១ | ០ |
| ៦ | ប័ណ្ណបញ្ជូន | ៥០ | ២០ | ២០ | ១០ | ០ |
| ៧ | សៀវភៅព័ត៌ផ្កាឈូក | ៨០ | ៣០ | ២០ | ២០ | ១០ |
| ៨ | ខិតប័ណ្ណអប់រំផ្សព្វផ្សាយ | ១០,០០០ | ៣០០ | ៥០០ | ១០០ | ១០០ |
| ៩ | សៀវភៅជម្រើសនៃការមានផ្ទៃពោះ | ៦០០ | ០ | ៣០០ | ១៥០ | ១៥០ |

## ២.២.២ គម្រោង៖ អាជីវកម្មខ្នាតតូច (Financing Future Project)

| | |
|---|---|
| *ក. គោលបំណង* | ៖ ការធ្វើឱ្យប្រសើរឡើងនូវជីវភាពគ្រួសារ និងអាចមានលទ្ធភាពក្នុងការបញ្ជូនកូនឱ្យទៅសាលារៀន។ |
| *ខ. ចំនួនបុគ្គលិកសរុប* | ៖ ១ នាក់ ស្រី: ០ នាក់ |
| *គ. ទីតាំងគម្រោង* | ៖ ខេត្តកំពង់ចាម |
| *ឃ. សរុបថវិកាគម្រោង* | ៖ ៩,៥០០.០០ ដុល្លារ |
| *ង. កាលបរិច្ឆេទគម្រោង* | ៖ ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩ |

*ច. សកម្មភាពអនុវត្តគម្រោង៖*

### ១). ផ្តល់ការបណ្តុះបណ្តាល ផែនការអាជីវកម្មខ្នាតតូច និងផ្តល់ប្រាក់កម្ចី មុនពេលដែលយើងបានផ្តល់នូវប្រាក់កម្ចី

សមាជិកម្នាក់ៗ បានទទួលវគ្គបណ្តុះបណ្តាលមុនទទួលថវិកា។ វគ្គបណ្តុះបណ្តាលនេះបានផ្តល់ចំណេះដឹងដល់អ្នកទទួលផលជាច្រើនអំពី៖ ការរៀបចំផែនការអាជីវកម្ម អនាម័យបរិស្ថាន សុខភាព និងផែនការហិរញ្ញវត្ថុ។




ការផ្តល់ប្រាក់ផ្តល់ប្រាក់ទុនមានចំនួនត្រឹមតែ ២០០ដុល្លារ ក្នុង ១ គ្រួសារ ឬតិចជាងនេះទៅតាមស្ថានភាពជាក់ស្តែង។ ការផ្តល់ប្រាក់ទុននេះសម្រាប់តែគ្រួសារក្រីក្រមានកូនរៀន ហើយចង់បង្កើត និងបង្កើនអាជីវកម្មរបស់ពួកគេ។ ការផ្តល់ប្រាក់ទុននេះចាប់ផ្តើមតាំងពីខែមិថុនា ឆ្នាំ ២០១៦ រហូតដល់បច្ចុប្បន្ននេះយើងមានអ្នកទទួលផលសរុបចំនួន ១១៥ គ្រួសារ។

| *បញ្ហាជួបប្រទះ* | *ដំណោះស្រាយ* |
|---|---|
| អ្នកទទួលផលមួយចំនួនពុំទាន់បានយល់ដឹងច្បាស់ពីផែនការអាជីវកម្មពេញលេញ ដូច្នេះធ្វើអោយពួកគាត់មានចំណេះដឹងមិនគ្រប់គ្រាន់ សម្រាប់ការងារមួយនេះ។ | បុគ្គលិក និងប្រធានក្រុម ចុះសហគមន៍ដើម្បីពន្យល់ពួកគាត់បន្ថែមអំពីអ្វីដែលគាត់បានរៀនពីផែនការអាជីវកម្ម។ |

### ២). ចុះត្រួតពិនិត្យ និងការបង្ហាត់បង្រៀនបន្ថែម

គ្រួសារនិមួយៗ ត្រូវបានចុះត្រួតពិនិត្យមួយខែម្តង ឬទៅតាមស្ថានភាពជាក់ស្តែង បុគ្គលិកគម្រោងបានចុះសាកសួរសុខទុក អំពីប្រាក់ចំណូល និងការចំណាយ ផែនការហិរញ្ញវត្ថុ មុខរបរ ការសិក្សារបស់កូនៗ របស់ពួកគេ ហើយក៏បានបង្រៀនបន្ថែមពីបច្ចេកទេសនៃការសរសេរចំណូលចំណាយ និងចំណេះដឹងផ្សេងៗ ពីអាជីវកម្មរបស់ពួកគេផងដែរ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
| --- | --- |
| អ្នកទទួលផលមួយចំនួនពុំទាន់បានយល់ដឹងច្បាស់អំពី ការកត់ត្រា ចំណូល និងចំណាយច្បាស់លាស់។ | បុគ្គលិក និងប្រធានក្រុម ត្រូវចុះណែនាំបន្ថែមអំពីសារៈសំខាន់នៃការការកត់ត្រា ចំណូល ចំណាយច្បាស់លាស់។ |

## ៣). ការ បង្កើតប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុន

អ្នកទទួលផលទាំងអស់អាចបង្វិលប្រាក់ទុនចូលក្រុមជួយខ្លួនឯងតាម ថ្ងៃ ខែ ដែលបានកំណត់ ឬទៅតាមស្ថានភាពជាក់ស្តែង។ ការលក់ដូរពួកគាត់ប្រចាំថ្ងៃអាចបង្កើនប្រាក់ចំណូលក្នុងគ្រួសារដើម្បីគាំទ្រការសិក្សាកូនៗ របស់ពួកគេ។ ប្រាក់ចំណូលជាមធ្យមចន្លោះពី ៣៥០,០០០ រៀល ទៅ ៤៥០,០០០រៀល។ ប្រាក់ចំណូលដែលគាត់ទទួលបានបង់ខ្លះមកក្រុមជួយខ្លួនឯង និងខ្លះទៀតសម្រាប់ផ្គត់ផ្គង់គ្រួសារនឹងជាពិសេសសម្រាប់ការសិក្សាកូនៗ របស់ពួកគេ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
| --- | --- |
| ការសងប្រាក់ទុនមានការយឺតយាវនៃការសងប្រាក់ទុនត្រលប់មកក្រុមវិញ។ | បុគ្គលិកផ្តល់យោបល់ និងអនុញ្ញាតអោយពួកគាត់បង់តាមលទ្ធភាពដែលមាន មិនចាំបាច់តាមតារាងកំណត់ឡើយតែយ៉ាង ហើចបានជារៀងរាល់ខែ ទោះបីតិចក៏ដោយ។ |

## ៤). ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់

ការប្រជុំប្រចាំខែត្រូវបានធ្វើ នៅស្រុកកំពង់សៀម និងកំពង់ចាម។ វាមានសារៈសម្ខាន់ណាស់ចំពោះសមាជិកដែលពួកគេអាចជួយគ្នាទៅវិញទៅមក ដោយសមាជិកក្រុមទាំងអស់យកលុយមកដាក់ក្រុមហើយអនុញ្ញាត្តិអោយក្រុមខ្ចីលុយក្នុងសមាជិកក្រុមរបស់ពួកគាត់។ ចំណែកឯការកត់ត្រា និងត្រួតពិនិត្យ គឺប្រធានក្រុម និងបុគ្គលិកជាអ្នកជួយសម្របសម្រួល។ កំឡុងពេលប្រជុំសមាជិកក្រុមបានប្រមូលប្រាក់កម្ចីមកវិញតាម កិច្ចសន្យាដែលបានចែង។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
| --- | --- |
| សមាជិកក្រុមសន្សំប្រាក់មានចំណេះដឹងតិចតួច និងពុំទាន់យល់ដឹងច្បាស់អំពីដំណើរការសន្សំប្រាក់ជួយខ្លួនឯង។ | បុគ្គលិក ប្រធានក្រុមបានធ្វើសមាធិប្រមូលអារម្មណ៍ និងជួយបង្ហាត់បង្រៀនបន្ថែមដល់ក្រុមសន្សំប្រាក់ទាំងអស់កំឡុងពេលប្រជុំប្រចាំខែ។ |

## ២.២.៣- គម្រោង៖ ការធ្វើអោយប្រសើរឡើងនូវជីវភាព (Chicken Raising Project)

| | |
|---|---|
| *ក. គោលបំណង* | ៖ ជួយអ្នកផ្ទុកមេរោគអេដស៍ក្នុងតំបន់គោលដៅ ដើម្បីលើកកម្ពស់សន្តិសុខនិងសុខភាពជីវភាពរស់នៅរបស់ពួកគេ |
| *ខ. ចំនួនបុគ្គលិកសរុប* | ៖ ១ នាក់ ស្រី ០ នាក់ |
| *គ. ទីតាំងគម្រោង* | ៖ ខេត្តត្បូងឃ្មុំ |
| *ឃ. សរុបថវិកាគម្រោង* | ៖.៤,៥០០ ដុល្លារ |
| *ង. កាលបរិច្ឆេទគម្រោង* | ៖ ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩ |

*ច. សកម្មភាពអនុវត្តគម្រោង៖*

### ១). ផ្តល់ការបណ្តុះបណ្តាល ផ្នែកចិញ្ចឹមមាន់ និងផ្តល់ប្រាក់ទុន មុនពេលដែលយើងបានផ្តល់នូវប្រាក់ទុន

សមាជិកម្នាក់ត្រូវចូលរួមការបណ្តុះបណ្តាលមួយវគ្គ។ អ្នកទទួលផលត្រូវយល់ដឹងអំពីអនាម័យបរិស្ថាន សុខភាព និងចាក់ថ្នាំបង្ការ ការបែងចែកចំណាត់ថ្នាក់មាន់ ដែលមានអាយុ និងមាឌខុសគ្នាដាក់ដោយឡែក និងពិនិត្យមើល តម្លៃនៅលើទីផ្សារតាររដូវកាលនិមួយៗ ដើម្បីអោយច្បាស់ថាអាចនាំចូលក្នុងទីផ្សារបាន។

ការផ្តល់ប្រាក់ទុនសម្រាប់ឆ្នាំ ២០១៥ ត្រូវបានបញ្ចប់នៅក្នុងខែមិថុនារួចរាល់ហើយ។ ចំណែក១៨ គ្រួសារទៀតដែលស្ថិតនៅក្នុងស្រុក អូររាំងឪ និងស្រុកពញាក្រែកទទួលបានប្រាក់ទុនចំនួន ១២០$។ ជាជំហានដំបូងនៃដើមខែមិថុនាពួកគេទទួលបាន ៦០ $ ដើម្បីទិញសម្ភារសម្រាប់ ទ្រុងមាន់។ លើកទីពីរពួកគាត់ទទួលបាន ៦០ដុល្លាទៀតយកទៅទិញពូជមាន់មកចិញ្ចឹម ទិញចំណី និងថ្នាំបង្ការ។

| *បញ្ហាជួបប្រទះ* | *ដំណោះស្រាយ* |
|---|---|
| អ្នកទទួលផលមួយចំនួនពុំទាន់បានចូលរួមវគ្គបណ្តុះបណ្តាលពេញលេញ ដូច្នេះធ្វើអោយពួកគាត់មានចំណេះដឹងមិនគ្រប់គ្រាន់ សម្រាប់ការងារនេះ។ | បុគ្គលិកចុះសហគមន៍ ដើម្បីពន្យល់ពួកគាត់ និងបង្ហាត់បង្រៀនបន្ថែមអំពីហានិភ័យនៃការចិញ្ចឹមមាន់ប្រកបដោយប្រសិទ្ធភាពខ្ពស់។ |

### ២). ចុះត្រួតពិនិត្យ និងបង្រៀនការចិញ្ចឹមមាន់

គ្រួសារនិមួយៗ ត្រូវបានចុះត្រួតពិនិត្យមួយខែម្តង ឬទៅតាមស្ថានភាពជាក់ស្តែង។ បុគ្គលិកគម្រោងបានត្រួតពិនិត្យនូវប្រាក់ចំណូល និងការចំណាយផ្នែកមុខរបរចិញ្ចឹមមាន់ ហើយក៏បានបង្រៀនបន្ថែមពីបច្ចេកទេសនៃការថែរក្សា និងការចិញ្ចឹមមាន់ ការជួសជុលថែទាំទ្រុងមាន់ និងការចុះស្រង់តម្លៃទីផ្សារ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| អ្នកទទួលផលមួយចំនួនមិនទាន់មានទំនុកចិត្ត ទៅលើរបៀបនៃការផ្តល់ចំណី និងថែទាំមាន់ | បុគ្គលិកត្រូវផ្តល់ពីររបៀបការផ្តល់ចំណី គឺទៅតាម អាយុរបស់មាន់ អនាម័យ សំអាតទ្រុង និងដាក់ទឹក អោយមាន់ផឹកទៀងពេល។ |

## ៣). ការបង្កើន ប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់ទុននៃការចិញ្ចឹមមាន់

គ្រួសារទាំងអស់អាចបង្វិលប្រាក់ទុនមកក្រុមវិញតាមថ្ងៃខែដែលបានកំណត់។ ពួកគាត់បានលក់មាន់ ពីរដងក្នុងមួយឆ្នាំ ទទួលបានប្រាក់ចំណូលប្រមាណ ពី ៥០០,០០០៛ ទៅ ៧០០,០០០៛។ បន្ទាប់ពីពួកគេបានលក់ហើយម្តង គាត់បានបង្វិលប្រាក់ទៅក្រុមវិញ ហើយខ្លះនៅបន្តការស្នើរសុំប្រាក់ទុនថ្មីម្តងទៀត

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ពេលលក់មាន់ៗ ចុះថ្លៃ | បុគ្គលិកចុះ សហគមន៍ និងជំរុញពួកគាត់លក់មាន់ នៅរដូវកាលដែលគេត្រូវការ ដូចជារដូវកាល ថ្ងៃឈប់សម្រាក់ បុណ្យជាតិ ធំៗ របស់ខ្មែរ ឬចិន ទើបបានថ្លៃ។ |
| អ្នកទទួលផល ៥គ្រួសារ មិនទាន់មានលទ្ធភាពបង្វិលប្រាក់ទុនមកក្រុមវិញបាន។ | បុគ្គលិក ផ្តល់យោបល់ និងអនុញ្ញាតអោយពួកគាត់បង់តាមលទ្ធភាពដែលមាន មិនចាំបាច់តាមតារាងកំណត់ឡើយ តែយ៉ាងហើចបានជារៀងរាល់ខែ ទោះបីតិចក៏ដោយ។ |

## ៤). ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់



ការប្រជុំប្រចាំខែត្រូវបានធ្វើ នៅស្រុកអូររាំងឪ និង ពញាក្រែក មានសារៈសំខាន់ណាស់ចំពោះសមាជិកដែលពួកគេអាចជួយគ្នាទៅវិញទៅមក ដោយសមាជិកក្រុមទាំងអស់យកលុយមកដាក់ក្រុមហើយអនុញ្ញាត្តិអោយក្រុមខ្ចីលុយក្នុងសមាជិកក្រុមរបស់ពួកគាត់។ ចំណែកឯការកត់ត្រា និងត្រួតពិនិត្យ គឺប្រធានក្រុមនិងបុគ្គលិកជាអ្នកជួយសម្របសម្រួល។ កំឡុងពេលប្រជុំសមាជិកក្រុមបានប្រមូលប្រាក់កម្ចីមកវិញតាម កិច្ចសន្យាដែលបានចែង។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ក្រុមសមាជិកប្រាក់សន្សំប្រាក់មិនមានការតាំងចិត្តនិងគោលបំណងខ្ពស់ក្នុងការចូលរួមក្នុងក្រុម | បុគ្គលិកបានធ្វើសមាធិប្រមូលអារម្មណ៍ និងណែនាំបន្ថែមពីសារៈសំខាន់ របស់ក្រុមសន្សំប្រាក់។ |

## ២.៣- កម្មវិធីអភិបាលកិច្ចល្អ

### ២.៣.១- គម្រោង៖ គណនេយ្យភាពសង្គម ធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ

ក. គោលបំណង ៖ ពង្រឹងតំរូវការនៃគណនេយ្យភាពសង្គមនៅក្នុងដំណើរការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីកែលម្អការផ្តល់សេវាសាធារណៈនៅកម្ពុជា។

ខ. ចំនួនបុគ្គលិកសរុប ៖ ២ នាក់ ស្រី ០ នាក់

គ. ទីតាំងគម្រោង ៖ ខេត្តកំពង់ចាម

ឃ. សរុបថវិកាគម្រោង ៖ ១៩,៥០៤.២១ ដុល្លារ

ង. កាលបរិច្ឆេទគម្រោង ៖ ខែកក្កដា ដល់ ខែធ្នូ ឆ្នាំ២០១៩

ច. សកម្មភាពអនុវត្តគម្រោង៖

១. លទ្ធផលសម្រេចបាន៖

ប្រជុំផ្សព្វផ្សាយ នឹងស្វែងរកការគាំទ្រជាមួយអ្នកពាក់ពន្ធ័(រដ្ឋបាលស្រុក ការិយាល័យអប់រំស្រុក ការិយាល័យសុខាភិបាលប្រតិបត្តិស្រុក អង្គការមូលដ្ឋាន មេឃុំ នាយកសាលា មណ្ឌលសុខភាព ស្មៀន នឹង CAFs) ថ្នាក់ ស្រុកដែនមានអ្នកចូលរួមចំនួន ៥១នាក់ (ស្រី ១១នាក់) ។





ប្រជុំផ្សព្វផ្សាយ នឹងស្វែងរកការគាំទ្រជាមួយអ្នកពាក់ពន្ធ័ (មេឃុំនាយកសាលា មណ្ឌលសុខភាព ស្មៀន នឹង CAFs) ថ្នាក់ឃុំ ចំនួន ១២ឃុំ អ្នកចូលរួមចំនួន ១៩៩ នាក់(ស្រី ៣៦នាក់) ។





- ប្រជុំកំណាត់រកក្រុមជនអ្នករងគ្រោះថ្នាក់ឃុំ ចំនួន ១២ឃុំ អ្នកចូលរួមចំនួន ១៩៩ នាក់ (ស្រី ៣៦ នាក់) ។
- ប្រជុំជាមួយសហគមន៍ ដើម្បីផ្សព្វផ្សាយ I4C ស្តីពីសិទ្ធិ នឹងស្តង់ដា ចំនួន ១២ឃុំ ។
- ប្រជុំជាមួយសហគមន៍ ដើម្បីផ្សព្វផ្សាយ I4C ស្តីពីកញ្ចប់ថវិកា នឹងការអនុវត្តការងារ ចំនួន ១២ ឃុំ
- ផ្សព្វផ្សាយ I4C ចល័ត Kiosk នៅថ្នាក់ឃុំ ចំនួន ១២ ឃុំ
- កិច្ចប្រជុំផ្សាភ្ជាប់រវាងប្រជាពលដ្ឋ នឹងក្រុមងាយរងគ្រោះ ជាមួយក្រុមប្រឹក្សាឃុំ មណ្ឌលសុខភាព នឹងសាលារៀន ចំនួន ៥ ឃុំ គោលដៅ ។
- វគ្គបណ្តុះបណ្តាល៤ថ្ងៃទៅ CAFs ម៉ូដែលទី៣ ស្តីពី ការត្រួតពិនិត្យ នឹងតាមដានដោយប្រជាពលរដ្ឋ លើផ្នែកផ្តត់ផ្គង់សេវា អ្នកចូលរួមសរុបចំនួន ៤៣ នាក់(ស្រី ១៣ នាក់) ។
- បណ្តាញCAFs ថ្នាក់ឃុំ តំណាង CAFs ជ្រើសរើសបានចំនួន ១២ នាក់(ស្រី ១ នាក់)
- បណ្តាញCAFs ថ្នាក់ស្រុក តំណាង CAFs ជ្រើសរើសបានចំនួន ៥ នាក់(ស្រី ១ នាក់)
- ប្រអប់សមបុត្រ គណនេយ្យភាពសង្គម ចំនួន ១២ ឃុំ
- វគ្គបណ្តុះបណ្តាល ស្តីពីការគាំទ្រការរៀបចំសកម្មភាពសម្រាប់ការផ្លាស់ប្រែបែបវិជ្ជមាន ម៉ូឌុលទី៤ ទៅ CAFs ចំនួន ៤១ នាក់ស្រី ៩នាក់ ។

## ៤. បញ្ហាប្រឈម និងដំណោះស្រាយ៖

| ល.រ | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| ១ | CAFs មានការងាររវល់ច្រើន | បុគ្គលិកគម្រោងមានភាពបត់បែនផែនការធ្វើសកម្មភាពនៅពេលCAFs ទំនេរពីការងារស្រួល ។ |
| ២ | សកម្មភាពច្រើន | បុគ្គលិកគម្រោងមានគ្នាតិចសកម្មភាពគម្រោងច្រើន ធ្វើមិនទាន់ផែនការដែលបានគ្រោងទុក |
| ៣ | CAFs មានការផ្លាស់ប្តូរ | បុគ្គលិកគម្រោងបានសហការជាមួយប្រធានCAFs ថ្នាក់ឃុំជ្រើសរើសថ្មីមកជំនួស |
| ៤ | CAFs មួយចំនួនដល់រដូវច្រូតកាត់ | សមាជិកCAFs ផ្សេងៗមកចូលរួម នឹងជួយបង្ហាត់បង្ហាញអ្នកអត់បានមក |

## ៤.សន្និដ្ឋាន

អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលកំពុងបានទទួលមូលនិធិដោយផ្ទាល់ពីអង្គការក្រៅស្រុកដូចជាអង្គការ EcoSolidar (មកពីប្រទេសស្វីស) Rotary Club (មកពីប្រទេសកាណាដា) La Maison Dés Enfant (មកពីប្រទេសបារាំង) និង GlobeMed (មកពីចក្រភពអង្គេស) នឹងមូនិធិនៅក្នុងស្រុកដូចជាអង្គការ NORAD តាមរយៈ អង្គការ Save the Children, European Union តាមរយៈ អង្គការ World Vision International, Smile Restaurant, នឹង Hanchey Bamboo Resort ។ ដោយកំពុងតែបានអនុវត្តទៅលើកម្មវិធីធំៗចំនួនបី ដែលមានដូចជា៖ <u>(I). កម្មវិធីអបរំ៖</u> (១). គម្រោងកុមារមេគង្គកម្ពុជា (២). គម្រោងអប់រំមូលដ្ឋាន និង (៣). គម្រោងអបរំដើម្បីអណាគត់កុមារ <u>(II). កម្មវិធីសុខភាព៖</u> (១). គម្រោងធ្វើអោយប្រសើរឡើងនូវជីវភាពសហគមន៍ (២). អាជីវកម្មខ្នាតតូច និង (៣). គម្រោងផែនកាគ្រួសារ (III). កម្មវិធីអភិបាលកិច្ចល្អ (១). គម្រោងធ្វើអោយប្រសើឡើងរវាងអ្នកផ្តល់ និងអ្នកទទួលសេវា ដែលកម្មវិធីទាំងអសើនេះទាក់ទងទៅនឹងកម្មវិធីការអប់រំដល់កុមារក្រីក្រ កុមារងាយរងគ្រោះ កុមារបាត់បង់ឪកាស ពង្រឹងការអប់រំសិស្សកំរិតបឋម ពង្រឹងគុណភាពអប់រំតាមសាលា ការផ្តលជំនាញវិជ្ជាជីវៈ។ លទ្ធផលសម្រេចបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋ។

ជាងនេះទៀតអង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម សំណើសុំឲ្យមានការសហការបន្ថែមទៀតពីសំណាក់អាជ្ញាធរ និងសហគមន៍ពាក់ពាក់ព័ន្ធ ដើម្បីឲ្យលទ្ធផលនៃការអនុវត្តគម្រោងទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងគម្រោងនីមួយៗ ។

ថ្ងៃច័ន្ទ ២កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
កំពង់ចាម ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៩

បានឃើញនិងឯកភាព
**នាយកប្រតិបត្តិ**

**នាយកកម្មវិធី**